# និវេទនកថា

## Manifeste

Du Conseil de Transition Démocratique

ក្រុមប្រឹក្សាអន្តរកាលប្រជាធិបតេយ្យ

# និវេទនកថា

(Manifeste)

របស់ក្រុមប្រឹក្សាអន្តរកាលប្រជាធិបតេយ្យ

# មាតិកា


លំនាំដើម …………………………………………………………………………..…………..៤

១-គណបក្សប្រឆាំង …………………………………………………………………..………..៧

២-មូលហេតុនៅក្នុងប្រវត្តិសាស្ត្រនិងមូលហេតុនៅពេលថ្មីៗនៃមហាតុកម្មនាថ្ងៃ
ទី៧ ទី១៥ ទី១៦ និង ទី១៧ខែកញ្ញានៅទីក្រុងភ្នំពេញ ……………………………៩

៣-ប្រទេសកម្ពុជាសម័យទំនើបដែលគ្មានហ៊ុន-សែននិង គ្មានបក្សប្រជាជន ..១២

៤-សង្គមខ្មែរ ៖ សេរីភាព សិទ្ធិមនុស្ស លទ្ធិកុំម្មុយនិស្តនិង របបរាជានិយម…..១៤

៥- ប្រទេសកម្ពុជាដែលមាន ហ៊ុន-សែន / គណបក្សប្រជាជន
និង ប្រទេសកម្ពុជាដែលខ្មែរជំនាន់ក្រោយប្រាថ្នាចង់បាន …………………… ១៨

៦-ពលរដ្ឋខ្មែរ និង លទ្ធិកុំម្មុយនិស្ត ………………………………………..………១៩

៧-អត្ថន័យនៃបាតុកម្ម ………………………………………………………………….២១

៨-ទស្សនវិស័យ ……………………………………………………………………………២៣

៩-រដ្ឋាភិបាលដែលគ្មានពលរដ្ឋ និង រដ្ឋាភិបាលរបស់ពលរដ្ឋ ……..…………..២៦


CONSEIL DE TRANSITION DEMOCRATIQUE

# លំនាំដើម

ព្រឹត្តិការណ៍ដែលកើតមានឡើងនាពេលយុទ្ធនាការឃោសនាបោះឆ្នោតសភា នៃនីតិកាលទី៥ និង នៅពេលមហាបាតុកម្មនាថ្ងៃទី៧ ទី១៥ ទី១៦ និង ទី១៧កញ្ញា ឆ្នាំ២០១៣ នៅទីក្រុងភ្នំពេញ ជាសញ្ញាមួយប្រកបដោយអត្ថន័យច្បាស់លាស់ និងសំបូរបែប។ ពលរដ្ឋខ្មែរដែលមកទល់ពេលនេះ ត្រូវបានគេចាត់ទុកថា បានបណ្តែតបណ្តោយខ្លួនឲ្យពួកកាន់អំណាចផ្តាច់ការ ដែលប្រទេសមហាអំណាចបានដាក់បន្តុបពង្វក់ធ្វើបាបតាមទំនើងចិត្តរបស់ពួកវា បានបង្ហាញឲ្យឃើញនាថ្ងៃជាប្រវត្តិសាស្ត្រទាំងនោះ នូវការប្តេជ្ញាដ៏រឹងមាំរបស់គេថា នឹងបញ្ចប់ការប្រមាថកាតទានដែលពលរដ្ឋខ្មែរតាំងពីសម័យយូរលង់មកបានទទួលរងគ្រោះរហូត។ នៅក្នុងទំព័រប្រវត្តិសាស្ត្រខ្មែរយើង តាំងពីដើមរហូតមកទល់ពេលបច្ចុប្បន្ននេះ ការបះបោររបស់ប្រជានុរាស្ត្រមានមកជាហូរហែឥតមានដាច់ដូចជា ៖ ការបះបោរប្រឆាំងនឹងស្តេចអប្រិយផ្តាច់ការ ការបះបោរវាយរំលំលិទ្ធិព្រហ្មញ្ញសាសនានៅសតវត្សទី១៤ ការបះបោររបស់ស្តេចកននៅសតវត្សទី១៦(១៥១២-១៥២៦) កុបកម្មផ្សេងៗប្រឆាំងនឹងវត្តមានបារាំងនៅក្នុងស្រុក នៅសតវត្សទី១៩និងនៅដើមសតវត្សទី២០ បាតុកម្មនាថ្ងៃទី១៨មេសាឆ្នាំ១៩២៥ បាតុកម្មដឹកនាំដោយអ្នកស្នេហាជាតិមួយក្រុមនាថ្ងៃ ទី២០កក្កដា១៩៤២ ការតស៊ូដើម្បីលទ្ធិប្រជាធិបតេយ្យដែលអ្នកប្រជាធិបតេយ្យខ្មែរលើកដំបូងបង្អស់បានរៀបចំឡើងនៅឆ្នាំ១៩៤០ ការទម្លាក់សម្តេចនរោត្តម-សីហនុពីដំណែងប្រមុខរដ្ឋនា ថ្ងៃទី១៨មិនាឆ្នាំ១៩៧០ ជាដើម...។ល។ ទោះបីជាមានមតិខ្លះយល់ថា គឺជា ឧទ្ទាមកម្មដែលមិនបានទទួលលទ្ធផលអ្វីក្តីក៏ដោយ ក៏ពួកកាន់អំណាចផ្តាច់ការដ៏ឃោរឃៅ និងព្រហើនកោងកាចឥតកោតក្រែងទាំងនោះបាក់ស្បាតមិនតិចឡើយ ព្រោះពលរដ្ឋខ្មែរមិនរួញរានឹងដាក់ទោសប្រដៅឲ្យស្គាល់ខុសត្រូវឡើយ។ ជាការពិតណាស់ដែលថា នៅក្នុងដំណាក់កាលនិមួយៗ កុបកម្មទាំងឡាយនោះតែងតែបានជួបនឹងឧបសគ្គជៀសមិនផុត ប៉ុន្តែបើថាជាការឥតប្រយោជន៍ក៏មិនមែនដែរ ព្រោះដោយសារតែការប្រឆាំងទាំងនោះហើយ ដែលប្រជាជាតិខ្មែរបានឈានមកដល់ការ

ស្គាល់ពន្លឺនៃយុត្តិធម៌ នៃសេរីភាព និង នៃវឌ្ឍនភាពសព្វថ្ងៃនេះ។ គឺតាំងពីពេលនោះមកដែរ ដែលប្រជាពលរដ្ឋមានបទពិសោធន៍គ្រប់គ្រាន់យល់អស់សេចក្តីពីពួកវា ហើយមិនចាញ់បញ្ឆោតពួកវាទៀតឡើយ ពោលគឺគ្មានអ្វីដែលអាចធ្វើឲ្យគេបោះបង់ចោលការតស៊ូ ការកំណត់វាសនារបស់គេដោយងាយៗនោះឡើយ។

បាតុកម្មថ្ងៃទី៧ ទី១៥ ទី១៦ និងទី១៧ខែកញ្ញាឆ្នាំ២០១៣ ជាការបន្តខ្សែរយៈពីការប្រឆាំងនានានឹងពួកផ្តាច់ការដែលធ្វើបាបប្រជាជនយ៉ាងខ្លោចផ្សា គឺជាការប្រឆាំងដែលពលរដ្ឋខ្មែរធ្លាប់បានធ្វើជាហូរហែមក។ គណបក្សប្រឆាំងដែលពលរដ្ឋខ្មែរមួយភាគធំបានបោះឆ្នោតឲ្យ ដោយសង្ឃឹមថា ពួកគេនឹងអាចផ្លាស់ប្តូរការដឹកនាំប្រទេស មើលឃើញបាតុកម្មនោះថាគ្រាន់តែជាការទាមទារមួយដ៏សាមញ្ញរបស់ម្ចាស់ឆ្នោត ប្រឆាំងនឹងការបន្លំសន្លឹកឆ្នោតនិងការប្លន់លទ្ធផលឆ្នោតនៃពួកអ្នកកាន់អំណាចប៉ុណ្ណោះ ប៉ុន្តែគេមើលពុំឃើញ ស្តាប់ពុំឮសោះអំពីអ្វីៗដែលប្រជាពលរដ្ឋខ្មែរទាមទារ ៖ ប្រជាពលរដ្ឋខ្មែរទាមទាមទារឲ្យហ៊ុន-សែនចុះចេញពីអំណាចគឺមានន័យធំធេង ហើយខ្ពស់ជាងអ្វីដែលគណបក្សប្រឆាំងប្រាថ្នាចង់បានទៅទៀត ពោលគឺឆន្ទៈមិនអាចប្រែប្រួល និង មិនចេះរីងស្ងួតបាននៃប្រជាជាតិខ្មែរទាំងមូលដែលប្តេជ្ញាបញ្ចប់របបផ្តាច់ការមួយដែលស្ថិតនៅក្រោមអាណានិគមយួន តាំងពីឆ្នាំ១៩៧៩មក និងបញ្ចប់អនុត្តរភាពរបស់ប្រទេសយួននិងចិនកុំម្មុយនិស្ត ដែលបានគ្របដណ្តប់មកលើប្រទេសកម្ពុជាតាំងពីពេលដែលកងទ័ពបារាំងចេញផុតទៅ។

បាតុកម្មនេះ មិនមែនជាបាតុកម្មលើកដំបូងនៅក្នុងទំព័រប្រវត្តិសាស្រ្តនៃប្រទេសកម្ពុជានាសហសម័យយើងនេះទេ ប៉ុន្តែម្តងនេះ គឺជាការភ្ញាក់រលឹក របើបម្រះចេញពីសុបិនអាក្រក់របស់ប្រជាពលរដ្ឋដែលត្រូវគេជិះជាន់សង្កត់សង្កិនជាន់ឈ្លីនឹងជើង។

ពលរដ្ឋខ្មែរ បានត្រូវគេយកទៅជីកកប់នៅក្នុងរណ្តៅនៃភាពអន្ធការមួយដែលគេមិនអាចអត់ឱនឲ្យបាន តាំងពីពេលដែលយួនបានអនុវត្តនយោបាយសហពន្ធ័ឥណ្ឌូចិនមកលើកម្ពុជានិងលាវចាប់ពីឆ្នាំ១៩៣០មក ហើយដែលប្រទេសកម្ពុជាបានចងសម្ព័ន្ធភាពជាមួយប្រទេសចិននៅទសវត្ស៦០។ ទោះជាយ៉ាងនេះក្តី

ក៏ពលរដ្ឋខ្មែរបានចេញផុតពីសភាពការណ៍នេះដែរនៅទីបំផុត ដោយសារគេមានលទ្ធភាពក្រេបជញ្ជក់យកការពិតតាមប្រព័ន្ធផ្សព្វផ្សាយដោយបច្ចេកវិជ្ជាទំនើប។ នៅពេលបច្ចុប្បន្ននេះជាងពេលណាៗទាំងអស់ គេប្ដេជ្ញារំដោះខ្លួន រំដោះប្រទេសជាតិ រំដោះប្រជាជាតិខ្មែរ ឲ្យចេញផុតពីអាណានិគមយួននិងចិន ដែលស្ដេចសីហនុបានបើកផ្លូវឲ្យចូលមកធ្វើបាបពលរដ្ឋខ្មែរ។ ឥឡូវនេះអ្វីៗលែងដូចមុនទៀតហើយ ខ្មែរគ្រប់រូបបានយល់អស់សេចក្ដីពីពុតត្បុតរបស់ពួកវា។ ដោយសារប្រព័ន្ធផ្សព្វផ្សាយតាមបច្ចេកវិជ្ជាទំនើបៗ ការភូតភរផែតកោតក្រែងនិង ការប្រើភាសាបោកប្រាស់ដោះសាបំភាន់មតិរបស់ពួកវា ត្រូវបានពលរដ្ឋខ្មែរសើចចំអកពេញប្រទេស។ អស់រយៈពេលកន្លះសតវត្សកន្លងមកនេះ ពលរដ្ឋខ្មែរត្រូវបានពួកអាណានិគមថ្មីទាំងពីរនេះដាក់ឲ្យស្ថិតនៅក្នុងភាពល្ងង់ខ្លៅ ក្នុងភាពច្របូកច្របល់ផ្លូវគំនិត យកខុសជាត្រូវ យកខ្មៅជាស យកការខិលខូចកោងកាច និងភាពល្ងង់អវិជ្ជាធ្វើជាគំរូសង្គម ពោលគឺ គេបានប្រាថនាឲ្យពលរដ្ឋខ្មែរធ្លាក់ទៅក្នុងយន្ដការចុះដុនដាប ដូចជាការជំរុញឲ្យប្រមាថសីលធម៌ និង រិះគន់បង្អាប់បង្អោនអ្នកមានគុណធម៌ បន្ទុះបង្អាប់អ្នកដែលមានគុណូបការពិតប្រាកដជាដើម។ល។ បាតុកម្មនាថ្ងៃទី៧ ទី១៥ ទី១៦ និង ទី១៧កញ្ញា ជាការបើកសករាជមួយថ្មីសម្រាប់ប្រជាជាតិខ្មែរយើង៖ វិធីសាស្ត្រចាស់គំរឹលដែលពួកផ្ដាច់ការពួនក្រោយរបាំងនៃលទ្ធិប្រជាធិបតេយ្យក្លែងក្លាយ លែងមានប្រសិទ្ធិភាពទៅលើយុវវ័យនាបច្ចុប្បន្នកាលនេះទៀតហើយ ព្រោះយុវវ័យសម័យឥឡូវនេះគេត្រៀមលក្ខណៈជាស្រេច ដើម្បីនាំប្រទេសរបស់គេឲ្យចូលទៅក្នុងពិភពលោកសម័យទំនើប។ តាមរយៈព្រឹត្តិការណ៍បាតុកម្មជាប្រវត្តិសាស្ត្រនេះ គេត្រូវមើលឲ្យឃើញថា វីរភាពដ៏អង់អាចក្លាហានរបស់ពលរដ្ឋខ្មែរ គឺមានយ៉ាងពិតប្រាកដ ហើយមិនដូចអ្វីៗដែលអ្នកខ្លះតែងតែនិយាយបន្ទាបបន្ថោកកន្លងមកនោះទេ។ ពួកអ្នកដែលធ្លាប់ស្មានឬដែលនៅតែជឿថា ពួកគេអាចបង្វិលខួរក្បាលខ្មែរ ដោយញុះញង់មិនឲ្យខ្មែរដើរដល់គោលដៅដែលគេបានកំណត់តាំងពីសម័យយូរលង់មកហើយនោះ កំពុងតែយល់ច្រឡំធំហើយ។ បាតុកម្មនាថ្ងៃទី៧ ទី១៥ ទី១៦ និង ទី១៧កញ្ញា ជាការបង្ហាញឲ្យឃើញយ៉ាងប្រត្យក្ស នូវសេចក្ដីក្លាហានរបស់ខ្មែរនៅទីបំផុត គឺការសំដែងចេញឲ្យឃើញ

យ៉ាងច្បាស់ នូវអ្វីៗដែលអ្នកខ្លះពុំជឿថា អាចមានទៅកើត។ ពេលបោះឆ្នោតសភានាថ្ងៃទី២៨កក្កដាឆ្នាំ២០១៣ ដែលគណបក្សសង្គ្រោះជាតិ បានចូលរួមដោយមានមូលហេតុផ្សេងៗរបស់គេផងដែរនោះ ជាឱកាសមួយដ៏ល្អសម្រាប់ឲ្យបាតុករបញ្ចេញនូវទឹកចិត្តរបស់គេយ៉ាងអធិកអធមនិងដ៏មហោឡារឹក។ នៅចំពោះមុខការសំដែងបដិហារដ៏ខ្លាំងក្លានេះ សូម្បីតែអ្នកនយោបាយ ទាំងខាងគណបក្សប្រឆាំង ទាំងខាងគណបក្សកាន់អំណាច ក៏មានការភ្ញាក់ផ្អើលស្រឡាំងកាំងយ៉ាងខ្លាំងដែរ។

ជនរួមជាតិជាទីគោរពបន្ទាប់ពីការអានសេចក្ដីផ្ដើមនៃវិវេទនាកថារបស់ក.អ.បថ្ងៃនេះនាងខ្ញុំសុំអានភាគបន្តជូនជនរួមជាតិស្ដាប់ដូចតទៅ

## ១- គណបក្សប្រឆាំង

ការបោះឆ្នោតសភាដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៨កក្កដាឆ្នាំ២០១៣ បានផ្ដល់សម្លេងភាគច្រើនទៅឲ្យគណបក្សសង្គ្រោះជាតិ ប៉ុន្តែដូចកាលពីការបោះឆ្នោតនានាក្រោយឆ្នាំ១៩៩៣ដូច្នោះដែរ គណបក្សប្រជាជនដែលក្ដាប់អំណាចរហូតមកទល់នីតិកាលនេះ បានបន្លំសន្លឹកឆ្នោតម្ដងទៀត ហើយនៅទីបំផុតបានបញ្ចេញកងកម្លាំងប្រដាប់អាវុធប្លន់លទ្ធផលឆ្នោតតែម្ដង ក្នុងគោលដៅរក្សាអំណាចរហូតដើម្បីបម្រើមហិច្ឆតារបស់ហាណូយនិងប៉េកាំង។ តាមការពិតទៅរដ្ឋប្រហារឆ្នាំ១៩៩៧ បានបញ្ចប់និស្សានុកូលភាពនៃរបបដែលអង្គការសហប្រជាជាតិបានរៀបចំឲ្យបាត់ទៅហើយ។ របបគ្រប់គ្រងដែលបានបន្តក្រោយរដ្ឋប្រហារ១៩៩៧ គ្រាន់តែជាការ វិលត្រលប់មករករបបដែលហាណូយបានបង្កើតនៅឆ្នាំ១៩៧៩តែប៉ុណ្ណោះ ប៉ុន្តែតួអង្គអ្នកនយោបាយខ្មែរ និង បណ្ដាប្រទេសដែលត្រូវគោរពកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ឆ្នាំ១៩៩១ បាននាំគ្នាតោងតាមរបបខុសច្បាប់នេះជារៀងរហូតមកនៅក្នុង ភាពមិនច្បាស់លាស់នៃផ្លូវច្បាប់មួយដ៏ច្របូកច្របល់ដើម្បីការពារផលប្រយោជន៍របស់គេរៀងៗខ្លួន។ ស្ថានភាពបែបនេះ បានធ្វើឲ្យពលរដ្ឋខ្មែរឈឺចាប់ឥតឧបមា ព្រោះហ៊ុន-សែន ដែលអាងមានថៅហ្វាយដែលជាមេដឹកនាំប្រទេសកុំម្មុយនិស្តនៅក្នុងតំបន់ បានបង្កើតរបបផ្ដាច់ការមួយដើម្បីរឹបអូសយក

ទ្រព្យសម្បត្តិ និង លុបបំបាត់សិទ្ធិសេរីភាពជាមូលដ្ឋានរបស់ពលរដ្ឋខ្មែរ។ យើងមិនបាច់និយាយរៀបរាប់រឿងដ៏កំសត់ទាំងអម្បាលម៉ានដែលហ៊ុន-សែន បានបង្ករឡើងដើម្បីធ្វើទុក្ខទោសពលរដ្ឋខ្មែរនៅក្នុងទំព័រនេះទេ ព្រោះអ្នកសារព័ត៌មាន និងប្រវត្តិវិទូបានលើកឡើងយ៉ាងក្បោះក្បាយរួចអស់មកហើយ។ រីឯរឿងដែលមិនទាន់បានលើកឡើង ហើយដែលត្រូវបានគេដឹងនៅពេលនេះ គឺអ្វីដែលបាតុករទាមទារយ៉ាងច្បាស់នៅពេលធ្វើបាតុកម្មជាប្រវត្តិសាស្ត្រនាថ្ងៃទី៧ ទី១៥ ទី១៦ និងទី១៧កញ្ញា ដែលជាព្រឹត្តិការណ៍មួយមិនធ្លាប់ដែលមាន ហើយដែលគ្មានគណបក្សនយោបាយណាមួយបានដឹងជាមុនថា មានលក្ខណៈដូចជាទឹកបាក់ទំនប់ និងធំធេងបែបនេះសោះ ៖ អ្វីដែលពលរដ្ឋខ្មែរទាមទារចង់បាននៅពេលបាតុកម្មនោះ គឺការចុះចេញពីអំណាចនៃអ្នកដឹកនាំផ្តាច់ការ ព្រមទាំងច្បាប់អយុត្តិធម៌ និងឥតន័យទាំងឡាយ ដែលរបបនេះបានបង្កើតឡើងដើម្បីសម្លាប់ពលរដ្ឋខ្មែរឲ្យផុតពូជរលត់ជាតិតែម្តង។ គណបក្សប្រឆាំងដែលមានគោលដៅមួយផ្សេងទៀតមិនសូវស្របនឹងឆន្ទៈដាច់ខាតនិងឥតប្រែប្រួលរបស់បាតុករ ក៏បានប្រើប្រាស់កម្លាំងបាតុកម្មនេះក្នុងគោលដៅអល់ឯកមួយ ដើម្បីបង្ខំឲ្យបក្សកាន់អំណាចចែកអំណាចជាមួយនឹងគេនៅក្នុងករណីព្រៀងទុកជាមុន ដែលគេមិនអាចយកឈ្នះទៅលើហ៊ុន-សែនបាន។ ទោះជាយ៉ាងណាក៏ដោយ ក៏គ្មានអ្វីដែលអាចបញ្ឈប់ ឬបន្ថយបង្អាក់ការងើបឡើងដូចព្យុះសង្ឃរានេះបានឡើយ ដោយហេតុថា បើរាជយគឺប្រជាជាតិទាំងមូលតែម្តងដែលត្រូវស្លាប់ ហើយអ្នកចំណេញគឺអនុត្តរភាពយួននិងចិនកុំម្មុយនិស្ត។ អ្នកនយោបាយគណបក្សប្រឆាំងចេះតែចង់ស្វែងរកការសម្រុះសម្រួលណាមួយជាមួយគណបក្សកាន់អំណាច ពោលគឺផ្លូវទី៣មួយដែលគ្មានទាល់តែសោះនៅក្នុងបរិបទនេះ ប៉ុន្តែត្រូវបង្ខំចិត្តប្រើកម្លាំងរបស់បាតុកម្មដោយគេចពុំផុត។ នៅក្នុងករណីដែលបក្សកាន់អំណាចប្រើកម្លាំងបង្ក្រាបបាតុកម្មតាមគ្រប់មធ្យោបាយដែលគេអាចធ្វើទៅបាន ក៏ពលរដ្ឋខ្មែរដែលធ្វើបាតុកម្មមិនបោះបង់ជំហររបស់គេជាដាច់ខាត។ គេនឹងបន្តការរំដោះខ្លួនគេ និងប្រទេសជាតិឲ្យចេញផុតពីនឹមបិសាចអាណានិគមយួននិងចិន នេះជាកំហិតជាដរាបតរៀងទៅ។ នៅពេលដែលតួអង្គអ្នកនយោបាយ ទាំងគណបក្សប្រឆាំង ទាំងគណបក្សកាន់

អំណាចរកប្រកចេញតាមការចរចាចែកអំណាចគ្នា ដោយយកផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍បក្សធ្វើជាធំ ហើយដែលខុសពីការទាមទាររបស់ប្រជាពលរដ្ឋទាំងស្រុង ពលរដ្ឋខ្មែរទូទាំងប្រទេសនឹងនាំគ្នារៀបចំអភិក្រមមួយដើម្បីរំដោះប្រទេសឲ្យចេញផុតពីនឹមអាណានិគមបរទេសឲ្យបានជាដាច់ខាត ព្រោះគេយល់ថា មិនអាចរង់ចាំពេលណាទៀតឡើយ គឺថាបើមិនពង្រឹងជំហររបស់គេនៅពេលនេះទេ នោះគេនឹងបាត់បង់ឱកាស ចុងក្រោយបង្អស់របស់គេនៅពេលនេះតែម្តង។ ទោះបីជាពួកអ្នកនយោបាយគ្រប់ប្រភេទ ព្រមទាំងចៅហ្វាយរបស់ពួកទាំងនោះបង្កើតឧបសគ្គរាំង និង ប្រើកល ល្បិចគ្រប់បែបយ៉ាងដើម្បីបង្អាក់ដំណើរយ៉ាងណាក៏ដោយក៏ពលរដ្ឋខ្មែរនៅតែ បន្តការតស៊ូរបស់គេបន្តទៅទៀតដែរ ៖ នៅពេលនេះ "ក្រុមប្រឹក្សាអន្តរកាលប្រជាធិបតេយ្យ" ត្រូវបានបង្កើតឡើងដើម្បីតំណាងឲ្យឆន្ទៈពិតប្រាកដនិងឥតប្រែប្រួលរបស់ពលរដ្ឋខ្មែរ មិនព្រមទទួលយកជាដាច់ខាតនូវការសម្រុះសម្រួលណាមួយជាមួយពួកកាន់អំណាចផ្តាច់ការ ហើយជាពិសេស នៅក្នុងន័យនេះ គឺមិនទទួលស្គាល់រដ្ឋសភាដែលបានកោះប្រជុំលើកដំបូងនៅថ្ងៃទី២៣កញ្ញាឆ្នាំ២០១៣ ព្រោះជារដ្ឋសភាដែលគ្មានតំណាងរាស្ត្រគណបក្សប្រឆាំងចូលរួម ពោលគឺជា "រដ្ឋសភាមិនស្របច្បាប់" ហើយក៏មិនទទួលស្គាល់រដ្ឋាភិបាលដែលកើតចេញពីរដ្ឋសភាក្លែងបន្លំនេះផងដែរ ព្រោះជារដ្ឋសភាដែលកោះប្រជុំដោយផ្អែកទៅលើ ការប្រកាសលទ្ធផលនៃការបោះឆ្នោតមួយដែលពោរពេញទៅដោយភាពមិនប្រក្រតី ហើយដែលពុំទាន់មានការដោះស្រាយឲ្យបានត្រឹមត្រូវនៅចំពោះមុខម្ចាស់ឆ្នោតនៅឡើយ។ មិនតែប៉ុណ្ណោះ ការបង្កើតសភាជាតិបែបនេះគឺជា"ការប្រមាថឆន្ទៈ"របស់ពលរដ្ឋខ្មែរយ៉ាងជាក់ស្តែង។

## ២- មូលហេតុនៅក្នុងប្រវត្តិសាស្ត្រ និង មូលហេតុនៅពេលថ្មីៗនៃមហាបាតុកម្មនាថ្ងៃទី៧ ទី១៥ ទី១៦ និង ទី១៧ខែកញ្ញាឆ្នាំ២០១៣ នៅទីក្រុងភ្នំពេញ

កិច្ចព្រមព្រៀងនៃសន្និសិទទីក្រុងហ្សឺណែវឆ្នាំ១៩៥៤ បានផ្តល់មកវិញដល់ប្រទេសកម្ពុជានូវសិទ្ធិទាំងឡាយដែលត្រូវបានបាត់បង់ បន្ទាប់ពីយួនកុំម្មុយនិស្តបានរំលោភអធិបតេយ្យខ្មែរ ដោយបានប្រើប្រាស់ទឹកដីខ្មែរបង្កប់ទ័ពយួនដើម្បីបង្កើតចលនាតស៊ូផ្សេងៗក្រោមការត្រួតត្រាគ្រប់គ្រងរបស់យួនកុំម្មុយនិស្ត ដូចជា ៖ ចលនាខ្មែរឥស្សរៈ ចលនាបង្រួបបង្រួមខ្មែរឥស្សរៈឬខ្មែរវៀតមិញ។ល។ ក្នុងគោលដៅអនុវត្តន៍នយោបាយសហពន្ធ័ឥណ្ឌូចិនរបស់យួនមកលើកម្ពុជានិងលាវចាប់ពីឆ្នាំ ១៩៣០ មក។ ប៉ុន្តែគួរឲ្យសោកស្តាយ ដោយស្តេចនរោត្តម-សីហនុបានប្រើកលល្បិចគ្រប់បែបយ៉ាងជាមួយសត្រូវដើម្បីបំផ្លាញកិច្ចព្រមព្រៀងនេះចោលទៅវិញ ហើយបានរុញច្រានប្រទេសកម្ពុជា ឲ្យធ្លាក់ក្នុងក្រញ៉ាំបិសាចពួកកុំម្មុយនិស្តយួន និងចិនតែម្តង។ មូលហេតុចំបង គឺស្តេចនរោត្តម-សីហនុ មានការច្រណែននិងស្អប់បញ្ញវន្តខ្មែរខ្លាំងណាស់ ព្រោះតែអ្នកទាំងនេះសុទ្ធតែជាអ្នកដែលប្រយុទ្ធតស៊ូដើម្បីសេរីភាពខ្មែរ និងរៀបចំស្ថាប័នជាតិនៃប្រទេសកម្ពុជាឲ្យមានលក្ខណៈទំនើប។

នៅឆ្នាំ១៩៥២ ស្តេចនរោត្តម-សីហនុបានធ្វើរដ្ឋប្រហារមួយទម្លាក់រដ្ឋាភិបាលខ្មែរដែលដឹកនាំដោយ**ហ៊ុយ-កន្ធុល** ហើយពេលនោះអ្នកប្រជាធិបតេយ្យត្រូវស្ថិតនៅក្នុងស្ថានភាពប្រកបដោយគ្រោះថ្នាក់បំផុត។ បស្ចិមប្រទេស មានប្រទេសបារាំងជាអាទិ៍ បានជួយរៀបចំកសាងប្រទេសកម្ពុជាឲ្យដើរតាមគន្លងឯករាជ្យរបស់ខ្លួន និងឲ្យបោះជំហានឈានចូលក្នុងអភិក្រមទំនើបកម្ម។ ប៉ុន្តែក្រោយឆ្នាំ១៩៥៣ នៅក្នុងបរិបទនៃសង្គ្រាមត្រជាក់រវាងលោកកុំម្មុយនិស្តនិងលោកសេរី ស្តេចនរោត្តម-សីហនុបានឆ្លៀតឱកាសជួយយួនកុំម្មុយនិស្ត ដោយបានអនុញ្ញាតឲ្យយួនបោះទីតាំងយោធានៅលើទឹកដីខ្មែរ ដោយសង្ឃឹមថា កុំម្មុយនិស្តអាចធ្វើឲ្យមានការរាំងស្ទះដល់អភិក្រមទំនើបកម្មរៀបចំតាមបែបបទបស្ចិមប្រទេស ដែលស្តេចនេះស្អប់ខ្ពើមជាទីបំផុត។ អ្នកស្នេហាជាតិជាច្រើននៅក្នុងនោះមានសម-សារី ព្រាប-អិន ចៅ-បុរី ជាដើម ត្រូវបាននរោត្តម-សីហនុបង្ខូចកេរ្តិ៍ ធ្វើឲ្យអាម៉ាសមុខ និងប្រហារជីវិតជាសាធារណៈយ៉ាងខ្លោចផ្សា។ បន្ទាប់ពីនរោត្តម-សីហនុបានបើកផ្លូវឲ្យកងទ័ពកុំម្មុយនិស្តយួនបោះទីតាំងនៅលើទឹកដីខ្មែររួច រដ្ឋសភានាសម័យនោះក៏បាន

បោះឆ្នោតទម្លាក់នរោត្តម-សីហនុពីអំណាចនៅថ្ងៃទី១៨មិនាឆ្នាំ១៩៧០ ព្រោះការអនុញ្ញាតឲ្យយួនបោះទីតាំងយោធានៅលើទឹកដីខ្មែរ វាជារឿងមួយប្រកបដោយគ្រោះថ្នាក់បំផុត។ ក្រោយការធ្លាក់ពីអំណាច នរោត្តម-សីហនុ ក៏ទៅចុះចូលជាមួយពួកខ្មែរក្រហម។ ដោយមានការអបអរសាទរពីប៉េកាំង និង កងទ័ពយួនកុំម្មុយនិស្ត នរោត្តម-សីហនុ ក៏ជំរុញឲ្យវាយរំលំរបបសាធារណរដ្ឋខ្មែរតែម្តង។ ក្រោយជ័យជម្នះនៅខែមេសាឆ្នាំ១៩៧៥ ប៉េកាំងមិនបានប្រគល់អំណាចឲ្យសីហនុទេ គឺបានប្រគល់ទៅឲ្យពួកខ្មែរក្រហមវិញ ហើយសីហនុមានតួនាទីត្រឹមតែជាទីងមោងសម្រាប់បោកប្រាស់ពលរដ្ឋខ្មែរបន្តទៅទៀតតែប៉ុណ្ណោះ។

របបខ្មែរក្រហមបានសម្លាប់ប្រជាជនខ្មែរអស់ជិតពាក់កណ្តាលនៃចំនួនប្រជាជនខ្មែរទាំងអស់។ កាលនោះបងប្អូនកុំម្មុយនិស្តទាំងពីរ គឺយួនកុំម្មុយនិស្ត និង ចិនកុំម្មុយនិស្តមានការទាស់ទែងគ្នាជាខ្លាំង។ ដោយមានជំនួយពីសហភាពសូវៀតហាណូយ បានវាយរំលំរបបខ្មែរក្រហមដើម្បីដកប៉ុលពតដែលជាកូនជឹងរបស់ចិន ហើយជំនួសដោយក្រុមខ្មែរក្រហមមួយទៀត ដែលជាឧបករណ៍នយោបាយដាច់ថ្លៃរបស់ខ្លួន គឺពួកគណបក្សប្រជាជនកម្ពុជា។ ។ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ថ្ងៃទី២៣តុលាឆ្នាំ១៩៩១ ពិតជាអាចបញ្ចប់សង្គ្រាមនេះ និងមហិច្ឆតាចិននិងយួនប្រសិនបើមានការអនុវត្តន៍ត្រឹមត្រូវ ហើយអាចផ្តល់ឲ្យកម្ពុជានិងពលរដ្ឋខ្មែរនូវអធិបតេយ្យ និង សិទ្ធិសេរីភាពមកវិញ។ ប៉ុន្តែចំពោះសីហនុ និងពួកកុំម្មុយនិស្តយួននិងចិន ការអនុវត្តន៍កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍មានន័យថា ជាការវិលត្រលប់មកវិញនៃក្រុមបញ្ញវន្តខ្មែរ ដែលនៅសេសសល់ពីការសម្លាប់រង្គាលរបស់អង្គការសហពន្ធ័ឥណ្ឌូចិន ដែលពួកវាស្អប់ខ្ពើមនិងរអែង ហើយដែលពួកវាមានផែនការណ៍សម្លាប់ឲ្យផុតពូជតែម្តង។

រដ្ឋប្រហារឆ្នាំ១៩៩៧ បាននាំប្រទេសកម្ពុជាឲ្យវិលទៅរករបបខុសច្បាប់ក្រោមអាណានិគមយួននាឆ្នាំ១៩៧៩វិញ ប៉ុន្តែបានយកឈ្មោះលទ្ធិប្រជាធិបតេយ្យមកប្រើក្លែងបន្លំដើម្បីបន្តយកជំនួយពីសហគមន៍អន្តរជាតិ។ ការបោះឆ្នោតដែល

មានជាហូរហែចាប់ពីពេលនោះមកសុទ្ធតែក្លែងបន្លំទាំងអស់ ធ្វើយ៉ាងណាឲ្យហ៊ុន-សែនបានកាន់អំណាចរហូត។ អ្នកនយោបាយខ្លះ ទោះបីមានមនោគមវិជ្ជាមិនមែនកុំម្មុយនិស្តក្តី ហើយខ្លះថែមទាំងប្រើផ្លាកប្រជាធិបតេយ្យបន្លំផងទៀតនោះ ក៏ចូលរួមក្នុងការបោះឆ្នោតក្រោមរូបភាពបត់បែននិងបំភាន់មតិពលរដ្ឋខ្មែរ ដែលជាការរំលោភលើស្មារតីនិងគោលការណ៍នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស២៣តុលា។ នៅក្នុងស្ថានភាពគ្មានតុល្យភាពត្រឹមត្រូវ គ្មានក្បាលកន្ទុយបែបនេះ យុវវ័យខ្មែរបាត់បង់អ្វីគ្រប់បែបយ៉ាងទាំងអស់ ៖ ទាំងកម្មសិទ្ធិ ទាំងអនាគតរបស់ពួកគេ។ ហ៊ុន-សែននិងក្រុមគ្រួសារដឹកនាំប្រទេសដោយប្រើការចាប់ចង ការកាប់សម្លាប់ ទាំងអ្នកប្រឆាំង ទាំងអ្នកគ្មានទោសពៃ ដែលត្រូវគេចោទដើម្បីឲ្យឧក្រិដ្ឋជនមែនទែនបានរួចខ្លួន។ គណបក្សប្រឆាំងដែលមានសម-រង្ស៊ី កឹម-សុខាជាមេដឹកនាំ ទោះបីដឹងជាមុនថា នឹងមានការក្លែងបន្លំសន្លឹកឆ្នោតគេចមិនផុតដូចពេលមុនៗ ក៏ពួកគេនៅតែចចេសចូលរួមបោះឆ្នោតនៅឆ្នាំ២០១៣ដដែល ទោះមានសមាជិកខ្លះរបស់ពួកគេបានពន្យល់យ៉ាងច្បាស់ថា ហ៊ុន-សែនត្រូវការចាំបាច់វត្តមានគណបក្សប្រឆាំងដើម្បីធ្វើបំភាន់មតិជាតិនិងអន្តរជាតិឲ្យគេឃើញថា ការបោះឆ្នោតនោះមានលក្ខណៈត្រឹមត្រូវតាមបែបបទប្រជាធិបតេយ្យ ពោលគឺវាគ្រាន់តែជាឆាកល្ខោនដែលគេរៀបចំឡើងដើម្បីបន្តយកជំនួយពីអន្តរជាតិតែប៉ុណ្ណោះ។ តែទោះបីពួកផ្តាច់ការបានប្រើវិធីបិសាចបែបនេះក្តី ពលរដ្ឋខ្មែរដ៏ច្រើនលើសលប់បាននាំគ្នាបោះឆ្នោតឲ្យគណបក្សប្រឆាំងដែលដឹកនាំដោយសម-រង្ស៊ី និង កឹម-សុខាដែរ។ ប៉ុន្តែអ្វីដែលពលរដ្ឋខ្មែរចង់បាននៅពេលដែលគេនាំគ្នាមកចូលរួមយ៉ាងសស្រាក់សស្រាំ ពពាក់ពពូនក្នុងមហាបាតុកម្ម គឺការទាមទារឲ្យហ៊ុន-សែនចុះចេញពីអំណាច ព្រោះការកាន់អំណាចបែបផ្តាច់ការរបស់ហ៊ុន-សែន ដែលស្ថិតនៅក្រោមខ្សែញាក់របស់ហាណូយនិងប៉េកាំង ជាប្រភពនៃទុក្ខទោសនិងវិនាសកម្មរបស់ពលរដ្ឋខ្មែរដែលបានត្រូវពួកនេះប្រមាថកាតទានជាច្រើនដងរួចមកហើយ។

## ៣- ប្រទេសកម្ពុជាសម័យទំនើប ដែលគ្មានហ៊ុន-សែន និងគ្មានគណបក្សប្រជាជន

បន្ទាប់ពីមានភាពច្របូកច្របល់ និងមិនច្បាស់លាស់ជុំវិញលទ្ធផលនៃការបោះឆ្នោតដែលមិនឆ្លុះបញ្ចាំងពីឆន្ទៈរបស់ខ្មែរ គណបក្សសង្គ្រោះជាតិហាក់មានចេតនាទាមទារយកជោគជ័យរបស់គេមកវិញ ដោយស្នើឲ្យមានការបង្កើតគណៈកម្មការត្រួតពិនិត្យឯករាជមួយដែលមានអង្គការសង្គមស៊ីវិល និងអង្គការសហប្រជាជាតិចូលរួមផង។ តែបន្ទាប់មក ក្នុងភាពមិនច្បាស់លាស់មួយ គណបក្សនេះ បែរជាចូលទៅធ្វើការចរចាចែកអំណាចជាមួយហ៊ុន-សែនទៅវិញ។ ដូចច្នេះ សឲ្យឃើញថា គណបក្សប្រឆាំងមានទស្សនៈភាន់ច្រឡំមួយដ៏ធំ បើប្រៀបធៀបទៅនឹងឆន្ទៈរបស់ប្រជាពលរដ្ឋដែលបាននាំគ្នាមកធ្វើបាតុកម្មនាថ្ងៃទី៧ ទី១៥ ទី១៦ និង ទី១៧កញ្ញា កន្លងមកនេះ ព្រោះបណ្តាបាតុករមិនបានទាមទារការចរចាទេ ពោលគឺទាមទារឲ្យហ៊ុន-សែនចុះចេញពីអំណាចតែម្តង ព្រោះតែអំណាចនេះស្ថិតនៅក្រោមបញ្ជារបស់ហាណូយនិងប៉េកាំង។ បាតុករគេត្រៀមលក្ខណៈជាស្រេច ដើម្បីដឹកនាំនិងសម្រេចវាសនារបស់គេដោយខ្លួនឯងទោះជា"មានឬមិនមានបក្សសង្គ្រោះជាតិ"ក្តី។ ទោះបីយ៉ាងណាក៏ដោយ ក៏ពួកគេមិនអាចដើរតាមសម-រង្ស៊ី និង កឹម-សុខាបានទេ នៅក្នុងករណីដែលមេដឹកនាំទាំងពីរនាក់នេះសុខចិត្តទៅចរចាចែកអំណាចជាមួយ ហ៊ុន-សែន។ អ្វីដែលគួរកត់សំគាល់ គឺគណបក្សប្រឆាំងហាក់មិនត្រឹមតែទៅចូលចរចាចែកអំណាចជាមួយហ៊ុន-សែនប៉ុណ្ណោះទេ តែថែមទាំងមានគម្រោងរក្សាអំណោចឲ្យហ៊ុន-សែនទៀត ដោយបានយករឿងបោះឆ្នោតលើកក្រោយមកនិយាយទៅវិញ គឺហាក់បីដូចជាគណបក្សប្រឆាំងសុខចិត្តទុកឲ្យ ហ៊ុន-សែន កាន់កាប់អំណាចបន្តទៅទៀត ពោលគឺព្រមឲ្យ ហ៊ុន-សែន កាប់សម្លាប់អ្នកប្រឆាំងរហូតដល់ផុតពូជតែម្តង។ នៅចំពោះមុខសភាពការណ៍បែបនេះ តើសម-រង្ស៊ី និង កឹម-សុខា មានលទ្ធភាពអ្វីដើម្បីទប់ស្កាត់សោកនាដកម្មនេះ? ពេលត្រឡប់មកកាន់អំណាចវិញ ហ៊ុន-សែន នឹងប្រើស្ថាប័ននានា ព្រមទាំងច្បាប់ដែលបានឬនឹងត្រូវបង្កើតឡើងសម្រាប់តែបង្ក្រាប និងរំលោភសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ មកធ្វើទុក្ខបុកម្នេញអ្នកប្រឆាំងជាមិនខាន ទោះបីជាប៉ះពាល់ដល់យុត្តិធម៌ និង ក្បត់ឆន្ទៈរបស់ប្រជាពលរដ្ឋក្តី។

## ៤- សង្គមខ្មែរ ៖ អំពីសេរីភាព សិទ្ធិមនុស្ស លទ្ធិកុំម្មុយនិស្ត របបរាជានិយម

បញ្ញវន្តខ្មែរនាទសវត្ស៤០ ៥០ ៦០ ៧០ ដែលនៅក្នុងចំណោមនោះ អ្នកមានឥទ្ធិពលជាងគេបានបង្កើត"គណបក្សប្រជាធិបតេយ្យ" បានបន្សល់ទុកដល់ខ្មែរជំនាន់ក្រោយនូវកេរ្តិ៍មរតកមួយដ៏សំខាន់ ទន្ទឹមនឹងរបបរាជានិយមនិងប្រពៃណីខ្មែរដែលមានប្រភពមកពីពុទ្ធសាសនា និង វប្បធម៌ហិណ្ឌូ។ ភាគច្រើននៃអ្នកទាំងនេះបានធ្វើការសិក្សានៅសាកលវិទ្យាល័យបារាំងមុននឹងចូលធ្វើសកម្មភាពនយោបាយនៅពេលត្រឡប់មកស្រុកវិញ។ ដោយនៅសម័យនោះ មានសាលារៀនបារាំង និងវិទ្យាល័យស្រាប់ ដូច្នេះអ្នកប្រជាធិបតេយ្យខ្មែរឈានមុខទាំងនោះពុំសូវមានការពិបាកប៉ុន្មានទេ ក្នុងការរុញច្រានសង្គមខ្មែរ ឲ្យវិវត្តឆ្ពោះទៅរកគំនិតទស្សនវិជ្ជា និងនយោបាយមនុស្សនិយម ដែលកាលនោះនៅមានលក្ខណៈថ្មីស្រឡាងនៅឡើយនៅក្នុងបរិបទនៃវប្បធម៌ខ្មែរ។ គឺនៅពេលនោះហើយ ដែលស្ថាប័ននយោបាយខ្មែរសម្របខ្លួនបណ្តើរៗទៅតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ។ នៅសម័យនោះការបញ្ចូលទស្សនវិជ្ជាមនុស្សនិយមតាមបែបបារាំង មកក្នុងវប្បធម៌ខ្មែរបានទទួលជោគជ័យជាវិជ្ជមាន ៖ កវី អ្នកនិពន្ធ ទស្សនវិទូ និង អ្នកនយោបាយ បាននាំគ្នាការពារគំនិតប្រជាធិបតេយ្យនៅក្នុងជីវភាពរស់នៅរបស់ខ្មែរ។ ប៉ុន្តែនៅពេលដែលកម្ពុជាកំពុងតែបោះជំហានសន្សឹមៗចូលទៅក្នុងពិភពសម័យទំនើបតាមរយៈទស្សនវិជ្ជាសម័យនោះ ស្រាប់តែស្តេចសីហនុបែរជារុញច្រានស្រុកខ្មែរឲ្យចូលទៅក្នុងស៊ីងប្រទេសកុំម្មុយនិស្តទៅវិញ ដោយបានធ្វើអ្វីគ្រប់បែបយ៉ាងដើម្បីត្រៀមលក្ខណៈប្រទេសកម្ពុជា ឲ្យហាត់រស់នៅតាមរបបផ្តាច់ការរបស់កុំម្មុយនិស្តទៅវិញ។ សីហនុ

បានបន្ទុចបង្អាក់មិនឲ្យមានការសិក្សាទស្សនវិជ្ជាទំនើបៗ ដែលការពារសិទ្ធិសេរីភាពបុគ្គល ដែលមានភាសាបារាំងនិងអង់គ្លេសជាភាសាយាន។ ការកាត់ផ្តាច់មិនឲ្យចរន្តទស្សនវិជ្ជាទាំងឡាយនេះចូលមក ត្រូវបានពួកខ្មែរក្រហម ដែលមានចិននិងយួននៅពីក្រោយ អនុវត្តយ៉ាងម៉ឺតម៉ាត់បំផុត ដោយបានកាត់សសៃគាស់រំលើងឫសកែវអស់គ្មានសល់នៅក្នុងស្ថានភាពមួយដ៏សាហាវយង់ឃ្នងបំផុត គឺការសម្លាប់បញ្ញវន្តខ្មែរដែលប្រើភាសាបារាំង និង អង់គ្លេសសឹងតែផុតពូជនៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ ព្រោះពួកអស់នេះចាត់ទុកថា គំនិតទាំងនេះជាគ្រោះថ្នាក់ដ៏ធំមួយដែលអាចធ្វើឲ្យរបបរាជានិយមរលំរលាយ ព្រោះថា ចិនកុំម្មុយនិស្តត្រូវការយករបបរាជានិយមធ្វើជាឧបករណ៍សម្រាប់សង្កត់សង្កិនពលរដ្ឋខ្មែរ។ អ្វីដែលធ្វើឲ្យពួករាជានិយមខ្មែរ និង ពួកកុំម្មុយនិស្តសហពន្ធ័ឥណ្ឌូចិនអាចសហការស្និតរមួតជាមួយគ្នាបាន ព្រោះមនោគមន៍វិជ្ជាសេរីនិយមនិងគំនិតការពារសិទ្ធិសេរីភាពមនុស្ស គឺជាឧបសគ្គមួយសម្រាប់រាជានិយមនិងរបបកុំម្មុយនិស្ត ព្រោះរបបរាជានិយមក៏ដូចកុំម្មុយនិស្ត ជាសត្រូវនឹងការប្រើសេរីភាព ព្រមទាំងភាពសំបូរបែបនៃគំនិត។ នៅបណ្តាទសវត្សទី៤០ ៥០ និង ៦០ បញ្ញវន្តខ្មែរមួយក្រុមដែលសិក្សានៅប្រទេសបារាំង ស្រឡាញ់លទ្ធិម៉ាក្សនិយម ហើយដែលតាមរយៈនោះ ចង់យកប្រទេសចិននិងសហភាពសូវៀតធ្វើជាគំរូសម្រាប់រៀបចំស្រុកខ្មែរ។ ពេលពួកគេត្រឡប់មកស្រុកខ្មែរវិញ គេបានសាកល្បងបញ្ចូលស្រុកខ្មែរទៅក្នុងពិភពកុំម្មុយនិស្ត បើនិយាយឲ្យខ្លី គឺចូលទៅក្នុងអង្គការចាត់តាំងរបស់អង្គការសហពន្ធ័ឥណ្ឌូចិនតែម្តង ដោយសារកាលនោះពួកកុំម្មុយនិស្តឥណ្ឌូចិនគេប្រយុទ្ធតស៊ូដើម្បីរំដោះប្រទេសគេឲ្យចេញផុតពីឥទ្ធិពលបស្ចិមប្រទេស។

និយាយពីសីហនុវិញ ដើម្បីយកឈ្នះទៅលើសឺង-ង៉ុកថាន់ ដែលជាអ្នកជាតិនិយមប្រឆាំងកុំម្មុយនិស្តនិងពួកឆ្វេងនិយម ហើយដោយសីហនុបានទទួលជំនួយពីបញ្ញវន្តអភិរក្ស(រាជានិយម)ផង និងដោយកម្ពុជាស្ថិតក្នុងបរិបទភូមិសាស្ត្រនយោបាយមិនច្បាស់លាស់ផង បារាំងក៏សុខចិត្តប្រគល់ឯករាជ្យ"សិប្បនិម្មិត"ទៅឲ្យសីហនុ។ ពេលបានឯករាជ្យហើយ សីហនុ ចាប់ផ្តើមច្រណែននិងស្អប់ខ្ពើមការ

ចេះដឹងរបស់បញ្ញវន្តដែលប្រឆាំងចិន និងយួនកុំម្មុយនិស្តដែលបានធ្វើសកម្មភាពបញ្ចុះបញ្ចូលសីហនុ។ ក្នុងគោលដៅកុំឲ្យមានឧបសគ្គរារាំង សីហនុ បានសម្លាប់ចោលអ្នកក្បាលរឹងទាំងនេះអស់មួយចំនួន ហើយដឹកនាំប្រទេសឲ្យធ្លាក់ទៅក្នុងកណ្តាប់ដៃចិននិងយួនកុំម្មុយនិស្ត ដែលប្រញាប់ដើរតួជំនួសអាណានិគមនិយមបារាំងនិងពួកអាមេរិកាំងនៅកម្ពុជា។ គួរកត់សំគាល់ថា ចាប់ពីពេលដែលយួនបានបង្កើត និង អនុវត្តនយោបាយអង្គការសហពន្ធ័ឥណ្ឌូចិននៅឆ្នាំ ១៩៣០ ពួកឆ្វេងនិយមខ្មែរបានធ្វើការតស៊ូនៅក្នុងក្របខ័ណ្ឌដ៏ទំលំទូលាយជាមួយពួកវៀតមិញ និងពួកកុំម្មុយនីស្តលាវដើម្បីដេញកងទ័ពបារាំង និង បញ្ចប់ឥទ្ធិពលវប្បធម៌បារាំងឲ្យអស់ពីឥណ្ឌូចិន ។ ពួកខ្មែរក្រហមឬ ខ្មែរកុំម្មុយនិស្តបានឡើងកាន់អំណាចនៅឆ្នាំ ១៩៧៥ បានប្រានប្រទេសឲ្យធ្លាក់ទៅក្នុងឋាននរកអវចី ជាពិសេសទៅក្នុងទំនាស់រវាងចិននិងយួន។ នៅឆ្នាំ១៩៧៩ យួនកុំម្មុយនិស្តបានវាយរំលំពួកខ្មែរក្រហមនិន្នាការចិន ហើយដាក់នឹមអាណានិគមរបស់គេមកលើពលរដ្ឋខ្មែរតែម្តង។ មនោគមវិជ្ជាបស្ចិមប្រទេសដែលឈរនៅលើមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ និង សិទ្ធិមនុស្ស ក៏អស់ឥទ្ធិពលតាំងពីសម័យខ្មែរក្រហមឡើងកាន់អំណាចនោះមក។ បញ្ញវន្តខ្មែរដែលបានទទួលឥទ្ធិពលពីបារាំង បានត្រូវពួកខ្មែរក្រហមដែលមានចិននិងយួនជាចៅហ្វាយសម្លាប់ចោលសឹងតែអស់គ្មានសល់ សូម្បីតែជនកុំម្មុយនិស្តខ្មែរដែលរៀននៅស្រុកបារាំង ហើយដែលចេះត្រិះរិះពិចារណាក៏ពួកវាសម្លាប់ចោលដោយឥតអាសូរដែរ។ នៅក្រោមរបបខ្មែរក្រហមនេះ ប្រជាជនខ្មែរទាំងអស់ត្រូវពួកវាប្លន់យកផ្ទះសម្បែងនិងរិបអូសយកទ្រព្យសម្បត្តិគ្មានសល់។ នៅពេលដែលពួកខ្មែរក្រហមដែលមានយួនជាចៅហ្វាយ គឺបក្សប្រជាជនបដិវត្តន៍កម្ពុជាឡើងកាន់អំណាចនៅឆ្នាំ១៩៧៩ ពួកវាមិនបានសងផ្ទះមកឲ្យម្ចាស់ដើមគេវិញទេ គឺយកទៅបាត់រហូតតែម្តង។ ទោះបីជាយ៉ាងនេះក្តី ក៏ពួកវាប្រើពាក្យថា ”រំដោះ” ដែរ។ តែតាមការពិតវាគ្រាន់តែជាល្បិចកល និង ជាការដាក់អាណានិគមថ្មីមួយមកលើខ្មែរតាមដំណាក់ការយុទ្ធសាស្រ្តនយោបាយអាណានិគមរបស់ពួកវាប៉ុណ្ណោះ។ ពួកនេះបានបង្ខំឲ្យប្រជាពលរដ្ឋខ្មែរដែលនៅសល់ពីស្លាប់ ឲ្យទទួលយករបៀបរស់នៅមួយផ្សេងទៀតដែលខ្មែរពុំចង់បាន។ ម្តងនេះពួកវាមិនសម្លាប់បញ្ញវន្តដោយឆៅៗពេក

ដូចពេលមុននោះទេ គឺបើកបានទ្វារពីរ ៖ ឬមួយធ្វើជាសេក ជាខ្ញុំកញ្ជះរបស់ពួកវា ធ្វើជាទាសករនៃរបបកុំម្មុយនិស្តនិងបរិវារវា ឬមួយក៏រត់ចោលស្រុក។ អ្នកដែលជ្រើសរើសយកច្រកទី១ ត្រូវបានពួកវាដាក់នៅក្នុងនយោបាយអន្ទាក់និយមមួយបែបដែលមានការផ្សព្វផ្សាយចំណេះដឹងក្លែងក្លាយ គឺមានរហូតដល់ទៅសកលវិទ្យាល័យ ប៉ុន្តែគ្មានកម្មវិធីសិក្សាត្រឹមត្រូវអាចប្រើការបានដូចនៅប្រទេសនានាក្នុងសកលលោកទេ រីឯការចែកចាយគុណូបការវិញ គឺអយុត្តិធម៌ក្រៃលែង ជាហេតុធ្វើឲ្យប៉ះពាល់ជាទម្ងន់ដល់អង្គការចាត់តាំងចំណេះដឹងវិទ្យាសាស្ត្រទាំងមូល និងប្រព័ន្ធចំណេះដឹងពហុទស្សនៈ។ ច្រកទី២ អ្នកដែលបានជ្រើសរើសយកការរត់ចោលស្រុក ត្រូវបានបក្សពួករបស់វានៅក្រៅស្រុកធ្វើការគាបសង្កត់បន្តទៀត ដោយពួកអ្នកទាំងនោះបន្តបំរើផលប្រយោជន៍ចិននិងយួនកុំម្មុយនិស្ត ដោយហេតុផលផ្សេងៗ ។ ប៉ុន្តែបាតុកម្មនាថ្ងៃទី៧ ទី១៥ ទី១៦ និង ទី១៧កញ្ញា ជាពេលមួយដែលបញ្ញវន្តមិនចូលកុំម្មុយនិស្តនៃទសវត្សទី៦០ ដែលនៅសេសសល់ពីការសម្លាប់រង្គាល បានវិលត្រឡប់មកកសាងស្រុកសាជាថ្មីជាមួយយុវវ័យសព្វថ្ងៃ ដែលប្រាថ្នាចង់ឃើញប្រទេសខ្លួនវិវត្តតាមគន្លងគោលការណ៍ប្រជាធិបតេយ្យ តាមគោលការណ៍គោរពសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋពិតប្រាដក ដើម្បីដឹកនាំប្រទេសឆ្ពោះទៅរកវឌ្ឍនភាព។ នៅទសវត្សទី៤០ ៥០ និង ៦០ ប្រទេស កម្ពុជាបានស្គាល់របៀបរស់នៅតាមបែបបទទំនើបនេះម្តងរួចមកហើយៗពេលនោះអ្នកណាក៏មើលឃើញដែរថា ប្រទេសកម្ពុជាមានអនាគតល្អ ទោះបីបញ្ញវន្តឆ្វេងនិយមមួយចំនួនបានមើលឃើញដោយភាន់ច្រឡំថា លទ្ធិម៉ៅនិយម និងលទ្ធិម៉ាក្ស-លេនីនជាជម្រើសល្អក្តី ប៉ុន្តែក្រោយមកទើបគេដឹងរឿងពិតហើយស្តាយក្រោយ។ នៅពេលដែលហ៊ុន-សែន ចចេសបង្កើតរដ្ឋសភានិងរដ្ឋាភិបាលខុសច្បាប់នៅថ្ងៃទី២៣-២៤កញ្ញាតាមបញ្ជារបស់ប្រទេសជាចៅហ្វាយ និងប្រទេសដែលប្រមាថឆន្ទៈរបស់ប្រជាជនខ្មែរដូចហ៊ុន-សែនដែរនោះ បញ្ញវន្តឆ្វេងនិយមដែលបានទទួលរងគ្រោះដោយរបបកុំម្មុយនិស្តក៏ទទួលស្គាល់ស្មារតីរឹងប៉ឹង របស់ប្រជាពលរដ្ឋខ្មែរដែរ ហើយសារភាពកំហុសរបស់គេដោយរិះគន់ហ៊ុន-សែនដែលគេធ្លាប់បាន គាំទ្រពីពេលមុនយ៉ាងចាស់ដៃ។ អំណឹះតទៅបញ្ញវន្តខ្មែរទាំងអស់ នឹងចូលរួមក្នុងការតស៊ូ

ប្រឆាំងនឹងរបបហ៊ុន-សែន ហើយទទួលស្គាល់ថា សូម្បីតែ ឪពុកម្តាយ ជីដូនជីតារបស់គេក៏ស្រឡាញ់ចូលចិត្តរបបប្រជាធិបតេយ្យសេរីនិយម តាមបែបបស្ចិមប្រទេសដែរ គឺរបបដែលគេបានរស់នៅយ៉ាងរុងរឿងមុនការវាយលុករបស់ប្រទេសកុំម្មុយនិស្ត។

## ៥- ប្រទេសកម្ពុជាដែលមានហ៊ុន-សែន/បក្សប្រជាជន និង ប្រទេសកម្ពុជាដែលយុវវ័យ ប្រាថ្នាចង់បាន

ការមើលឃើញរបស់អ្នកនយោបាយដែលចាត់ទុកខ្លួនគេថា ជាអ្នកប្រជាធិបតេយ្យ និង ការមើលឃើញរបស់យុវវ័យសព្វថ្ងៃនេះ មិនដូចគ្នាដូចអ្នកខ្លះគេគិតជាទូទៅនោះទេ។ គេអាចមើលឃើញជាមុនថា ទោះបី សម-រង្ស៊ី បានបញ្ជាក់នូវនិន្នាការប្រជាធិបតេយ្យរបស់លោកនៅពេលឃោសនាបោះឆ្នោតក្តី ក៏លោកប្រហែលជាមានការរារែកខ្លះដែរ ក្នុងការអនុវត្តន៍អ្វីដែលយុវវ័យគេចង់បាន។ យុវវ័យចង់បានសេរីភាពនៃការគិត ពោលគឺសេរីភាពរបស់បុគ្គលម្នាក់ៗ សេរីភាពនៃការបញ្ចេញមតិ គឺមិនរណបនឹងការកំហិតគាបសង្កត់នានាឲ្យធ្វើតាមប្រពៃណី ដូចធ្លាប់មាននៅក្នុងរបបរាជានិយមកាលពីមុន គឺបែបបទដែលរាំងស្ទះដល់កត្តារីកចម្រើនផ្លូវបញ្ញា។ គេចង់ឲ្យមានកត្តារីកចម្រើននេះជាចាំបាច់ ដូចដែលប្រទេសប្រជាធិបតេយ្យធំៗគេបានកំណត់ដូច្នេះដែរ។ ប្រជាធិបតេយ្យរបស់ សម-រង្ស៊ី គឺការគោរពរបបរាជានិយម ហើយរក្សាទុកនូវជំនឿអរិជ្ជមានតាមបែបបទប្រជាភិថុត គឺមិនបើកផ្លូវឲ្យពន្លឺវិទ្យាសាស្ត្រកំណត់ជោគវាសនារបស់ប្រទេសនិងប្រជាពលរដ្ឋទេ។ បើដើរតាមផ្លូវនេះ យុវវ័យដែលចង់កសាងវាសនារបស់គេតាមគំនិតរបស់គេផ្ទាល់ ដូចនៅប្រទេសប្រជាធិបតេយ្យសេរីនិយម មុខជានឹងក្លាយទៅជាឧបករណ៍មួយសម្រាប់នាំមកវិញនូវការខុសឆ្គងននៃរបៀបរបបចាស់ជាមិនខាន។ ម្យ៉ាងទៀត នៅក្នុងន័យនេះ តើសម-រង្ស៊ី អាចបោះបង់ចោលផ្លូវ ដែលប៉េកាំងបានត្រួសត្រាយទុកសម្រាប់ត្រួតត្រាខ្មែរតាមរបៀបណាទៅ? ជាពិសេសអ្នកដែលសម្ព័ន្ធមិត្តចិនរក្សាទុកមកដល់សព្វថ្ងៃនេះ មានជាអាទិ៍ ស្តេច និង សម្តេចម៉ែជាភស្តុតាងស្រាប់? គេនៅមិន

ទាន់ដឹងនៅឡើយទេថា តើស្ថាប័នប្រជាធិបតេយ្យរបស់សម-រង្ស៊ីមានដំណើរការណ៍បែបណា បើសម-រង្ស៊ីនៅតែរក្សាប្រទេសចិនជាមិត្តពិសេសរបស់ខ្មែរដដែលនោះ? គេអាចនឹងធ្លាក់ទៅក្នុងរបបអភិជននិយមមួយប្រភេទ ដែលការផ្លាស់ប្តូរអ្នកដឹកនាំអាចមានដំណើររអាក់រអួលដូចពេលមុនៗដូច្នេះដែរ។ គេហាក់បីដូចជាមើលឃើញជាស្រេចថា ការប្រគល់អំណាចមកឲ្យយុវជនអ្នកដឹកនាំក្រោយៗ ដែលមាននិន្នាការស្រឡាញ់លទ្ធិប្រជាធិបតេយ្យសេរីនិយមតាមបែបបស្ចិមប្រទេស ពោលគឺរបបដែលយកប្រយោជន៍សាធារណៈជាធំ អាចចោទជាបញ្ហា។ ទស្សនៈប្រជាធិបតេយ្យរបស់កឹម-សុខា ដែលប្រហែលជាសម្រួលដល់ការផ្លាស់ប្តូរអ្នកដឹកនាំជាងទស្សនៈរបស់សម-រង្ស៊ី ក៏ហាក់មិនបានចាប់អារម្មណ៍ថា វាមានការវិវត្តន៍ជាច្រើននៅកម្ពុជាចាប់តាំងពីសម័យអ្នកប្រជាធិបតេយ្យខ្មែរតំបូងនៃទសវត្ស៤០។ តាំងពីពេលនោះមកទល់ពេលបច្ចុប្បន្ន ចិត្តគំនិតយុវវ័យខ្មែរមានការប្រែប្រួលច្រើនទៅតាមការរីកចម្រើននៃបច្ចេកវិជ្ជាទំនើបៗ គឺបច្ចេកវិជ្ជាដែលបាននាំឲ្យមានមហាបាតុកម្មនាថ្ងៃទី៧ ទី១៥ ទី១៦ និង ទី១៧កញ្ញានេះ។ ទោះជាយ៉ាងណាក្តី យុវជនជាច្រើនដែលបានចូលរួមក្នុងមហាបាតុកម្មនានេះ មើលឃើញអនាគតសង្គមខ្មែរឆ្ងាយជាងការមើលឃើញរបស់អ្នកទាំងពីរខាងលើនេះ គឺពួកគេចង់មានលទ្ធភាពគ្រប់គ្រាន់ ដើម្បីឈានឲ្យបានដល់កម្រិតសមត្ថភាពខ្ពស់បំផុតដូចយុវជននៅក្នុងលោកសេរី ប្រកបការងារស្របនឹងវិជ្ជាជីវៈ និង ទេពកោសល្យរបស់គេ ហើយលុបបំបាត់គំនិតគ្រួសារនិយម និងការព្រហើនកោងកាចរបស់កូនអ្នកអន្ទ្រើសចោលទាំងស្រុង គេចង់កសាងប្រទេសកម្ពុជាមួយដែលមានអធិបតេយ្យ ហើយដែលយល់ច្បាស់ពីសេរីភាពរបស់បុគ្គលនៅក្នុងវិស័យនយោបាយ។ ចំពោះយុវវ័យ ដើម្បីអាចឈានដល់នោះ គេត្រូវរំដោះខ្លួនឲ្យចេញផុតពីនឹមអាណានិគមនិយមរបស់យួន និងចិនសិន ពោលគឺចេញឲ្យផុតពីរបបហ៊ុន-សែន។

## ៦ ពលរដ្ឋខ្មែរ និង លទ្ធិកុំម្មុយនិស្ត

បន្ទាប់ពីមានបទពិសោធន៍នៅក្នុងរបបខ្មែរក្រហមប៉ុល-ពត និង របបខ្មែរក្រហមមួយទៀតដែលហាណូយបានដាក់បន្តុបឲ្យមានដំណើរការណ៍ចាប់ពីឆ្នាំ ១៩៧៩ មក ខ្មែរដែលមិនព្រមរណបហាណូយនិងប៉េកាំងយល់យ៉ាងច្បាស់ថា របបកុំម្មុយនិស្ត ជារបបដែលគួរឲ្យស្អប់ខ្ពើមជាទីបំផុត។ ប៉ុន្តែអន្តរាគមន៍របស់អង្គការសហប្រជាជាតិនៅឆ្នាំ១៩៩២ និង កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ឆ្នាំ១៩៩១ ពុំបានរំដោះប្រទេសកម្ពុជាពីក្រញាំកុំម្មុយនិស្តយួននិងចិនបានទេ។ រដ្ឋប្រហាររបស់ហ៊ុន-សែននៅឆ្នាំ១៩៩៧ បាននាំប្រទេសកម្ពុជាទៅរករបប៧មករាវិញដដែល គឺជារបបដែលយួនបានដាក់ឲ្យមាននៅស្រុកខ្មែរ ក្រោយការឈ្លានពានរបស់ពួកកុំម្មុយនិស្តយួន។ តាំងពីពេលនោះមក ពលរដ្ឋខ្មែរត្រូវទ្រាំទ្រការឈឺចាប់ខ្លោចផ្សាគ្រប់បែបយ៉ាង ហើយរង់ចាំតែឱកាសល្អដើម្បីរំដោះខ្លួនចេញពីហ៊ុន-សែនអ្នកបម្រើដែដល់របស់យួននិងចិន។ នៅពេលបន្តិចទៀតខាងមុខនេះ អ្នកដែលបានបោះឆ្នោតឲ្យហ៊ុន-សែននឹងមកចូលរួមជាមួយអ្នកស្នេហាជាតិ ដែលធ្វើការតស៊ូដើម្បីឯករាជ្យខ្មែរជាពុំខាន ព្រោះបន្តិចទៀតនេះ ហ៊ុន-សែននិងក្រុមគ្រួសារនឹងបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា ពួកគេដែលតាំងពីដើមមកការពារតែប្រយោជន៍របស់ហាណូយនិងប៉េកាំងនោះ នឹងការពារផលប្រយោជន៍របស់ប្រទេសទាំងពីរនេះខ្លាំងជាងមុនទៅទៀត។ យុវជនខ្មែរ នៅតែរកការងារធ្វើពុំបាន ទោះបីជាមានសញ្ញាប័ត្រអ្វីក៏ដោយ ហើយមិនតែប៉ុណ្ណោះ ពួកគេនឹងត្រូវគេប្រមាថមើលងាយចាត់ទុកថា ជាកូនពួកទាសករ ខណៈដែលឪពុកម្ដាយរបស់គេត្រូវពួកអាណានិគមចាត់ទុកថា ជាពពួកមនុស្សសំគិស មិនគួររាប់អាន ទោះបីគាត់នៅក្នុងស្រុករបស់គាត់សោះនោះក៏ដោយ។ គឺនៅពេលនោះហើយដែលរបបហ៊ុន-សែនត្រូវអស់លក្ខណ៍ ព្រោះនៅពេលនោះ ស្រុកខ្មែរត្រូវពួកយួននិងចិនចាត់ទុកថា ជាស្រុកយួនឬចិនហើយ ហ៊ុន-សែននិងបរិវាក៏នឹងគ្មានតួនាទីអ្វីទៀតឡើយដែរ គឺរលំរលាយដូចក្រមួនត្រូវថ្ងៃឬអំបិលត្រូវទឹកដូច្នេះឯង។ នៅក្នុងខណៈនេះដែលពលរដ្ឋខ្មែរនាំគ្នាធ្វើបាតុកម្មបញ្ចេញឆន្ទៈរបស់គេយ៉ាងគគ្រឹកគគ្រេង សហគមន៍អន្តរជាតិទុក

ពេលឲ្យខ្មែរដោះស្រាយបញ្ហាផ្ទៃក្នុងរបស់ខ្លួនសិន ប៉ុន្តែគេនឹងចូលធ្វើអន្តរាគមន៍នៅពេលមួយសមស្រប ព្រោះមួយចំណែក ប្រទេសចិនមិនត្រឹមតែគំរាមកំហែងប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែបន្តិចទៀតនេះនឹងគំរាមកំហែងពិភពលោកទាំងមូលដោយគេចពុំផុតឡើយ នៅពេលដែលចិនមានមធ្យោបាយគ្រប់គ្រាន់ ដូចពួកណាហ្ស៊ីអញ្ចឹងដែរ ហើយមួយចំណែកទៀត ប្រទេសយួនដែលចិនចង់យកទឹកដីដូចទីបេនោះ ក៏ប្រហែលជាត្រូវរកគេជួយជាពុំខាន។ ប៉ុន្តែនៅពេលបច្ចុប្បន្ននេះកុំម្ុយនិស្តទាំងពីរត្រូវរួបរួមគ្នាសិន នៅចំពោះមុខសហគមន៍ប្រជាធិបតេយ្យ ដើម្បីការពារដីដែលគេកំពុងដណ្តើមគ្នាកុំឲ្យសហគមន៍អន្តរជាតិធ្វើអន្តរាគមន៍បាន។ ចិនដែលដើរតួជាកាពីតែនឲ្យយួនធ្វើជាកាប៉ូរ៉ាល់ត្រួតត្រាខ្មែរជំនួស ហើយនឹងចែកផលប្រយោជន៍គ្នានៅពេលក្រោយ។

## ៧- អត្ថន័យនៃបាតុកម្មនាថ្ងៃទី៧ ទី១៥ ទី១៦ និង ទី១៧កញ្ញា

គេគួរយល់ឲ្យបានច្បាស់ថា មហាបាតុកម្មដ៏សម្បើមអស្ចារ្យនេះ គឺជាការសំដែងកំហឹងដ៏ពិតប្រាកដនិងដ៏ក្តៀវក្លារបស់ពលរដ្ឋខ្មែរទូទាំងប្រទេស ប្រឆាំងនឹងអ្នកកាន់អំណាច ព្រោះថា អ្នកដែលបានបោះឆ្នោតឲ្យហ៊ុន-សែនដោយបង្ខំមិនពេញចិត្តហ៊ុន-សែនឡើយ។ នៅពេលសមស្របខាងមុខ សូម្បីតែពួកអ្នកហ៊ុន-សែនដាច់ខាតពេលនេះ ព្រមទាំងសមាជិកគណបក្សប្រជាជនផង នឹងចូលមកក្នុងជួរអ្នកប្រឆាំងហ៊ុន-សែនដែរ គឺនៅពេលដែលអ្នកដឹកនាំបាតុកម្មមានទិសដៅស្របទាំងស្រុងនឹងឆន្ទៈពិតប្រាកដរបស់ប្រជាពលរដ្ឋ <u>គឺផ្លាស់ប្តូរអ្នកដឹកនាំប្រទេសឲ្យទាល់តែបាន</u>។ អ្នកដែលគាំទ្រហ៊ុន-សែនពុំមានចំនួនច្រើនប៉ុន្មានទេ ម្យ៉ាងទៀតអ្នកទាំងនេះ គាំទ្រហ៊ុន-សែនដើម្បីការពារតែប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេតែប៉ុណ្ណោះ។ គេអាចនិយាយបានថា "ហ៊ុន-សែន ដឹកនាំ ប៉ុន្តែគឺសមាជិកគ្រួសារគាត់និងបក្សពួករបស់គាត់ទេ ដែលជាអ្នកទទួលផលច្រើនជាងគេ"។ ខុសពីប៉េកាំងនិងហាណូយ ពួកនេះមិនគាំទ្រសោះឡើយដល់អ្នកដែលធ្វើឲ្យខូចប្រយោជន៍ពួកគេ។ លោកកាល់ម៉ាក្ស ធ្លាប់បានលើកឡើងពីបដិវាទកម្មនៅក្នុងលទ្ធិមូលធននិយម

រីឯបដិវាទកម្មនៃរបបដែលសាវ៉ែករបស់លទ្ធិម៉ាក្ស-លេនីន បានយកមកដាក់នៅស្រុកខ្មែរមានរូបភាពមួយទៀត គឺការរឹបអូសយកដីជាទ្រព្យសម្បត្តិរបស់ប្រជាជនឯង ហើយប្រល័យជីវិតប្រជាជនឯងទៀត។ នៅទីបផុត ពេលអស់ប្រជាជន វានឹងគ្មានអ្វីទៀតឡើយ គឺមានតែជនបរទេសប៉ុណ្ណោះ។ អ្នកខ្លះមើលឃើញថា ហ៊ុន-សែន មិនមែនខ្មែរទេ ហើយចេះគ្រប់គ្រងតែទាសករឬអ្នកទោសប៉ុណ្ណោះ រីឯរដ្ឋាភិបាលប្រជាធិបតេយ្យគ្រប់គ្រងអ្នកដែលចេះប្រើសេរីភាពរបស់គេ។ ដើម្បីបម្រើប្រយោជន៍របស់គាត់និងបក្សពួក ហ៊ុន-សែន មិនញញើតនឹងសម្លាប់ពួកអ្នកប្រឆាំងឲ្យផុតពូជឡើយ។ កងទ័ពខ្មែរពិត មិនហ៊ានធ្វើដូច្នេះទេ លើកលែងតែកងទ័ពបរទេសមកបន្លំជំនួស។

តើអ្នកឡើងកាន់អំណាចខុសច្បាប់នៅពេលនេះ អាចធ្វើព្រងើយកន្តើយនៅចំពោះមុខការទាមទាររបស់ពលរដ្ឋខ្មែរបានឬទេ? ចម្លើយ ៖ មិនអាចទេ ព្រោះថាគេមិនអាចផលិតអ្វីដោយគ្មានវត្ថុធាតុដើមនោះទេ គឺថាបើគ្មានពលរដ្ឋខ្មែរ ក៏គ្មានប្រជាជាតិខ្មែរដែរ។ ពេលដែលជនជាតិយួននិងចិនត្រូវបានយកមកដាក់ជំនួសពលរដ្ឋខ្មែរ ប្រទេសខ្មែរនឹងក្លាយជាឃុំមួយនៃស្រុកយួនឬស្រុកចិនប៉ុណ្ណោះ ហើយហ៊ុន-សែន ក្រុមគ្រួសារ និង បក្សពួកក៏លែងមានទៀតដែរ។ តែស្ថានការណ៍បែបនេះនឹងមិនអាចកើតមានបានឡើយ ដរាបណាខ្មែរនៅតែតស៊ូជានិច្ច។

បញ្ហាដែលចោទបច្ចុប្បន្ន ថាតើហ៊ុន-សែន អាចបន្តដឹកនាំស្រុកខ្មែរបានទេ នៅពេលដែលមានការទទូចពីបាតុករដែលទាមទារឲ្យ ហ៊ុន-សែន ចុះចេញពីអំណាច? ទោះបីជាមិនមានការចូលរួមពីគណបក្សសង្គ្រោះជាតិក៏ដោយ ក៏ប្រជាពលរដ្ឋដែលធ្វើបាតុកម្មនាថ្ងៃទី៧ ទី១៥ ទី១៦ និង ទី១៧កញ្ញា ច្បាស់ជាមិនព្រមទទួលយករបាំចាក់ត្លុកនេះជាដាច់ខាត ព្រោះថា បើហ៊ុន-សែននៅកាន់អំណាចដដែលនោះ អ្នកប្រឆាំងនឹងត្រូវគេធ្វើបាបនិងសម្លាប់ចោលដដែលជាដដែល ហើយរឿងបែបនេះសូម្បីតែកូនក្មេងក៏យល់ច្បាស់ដែរ គឺសម្លាប់ទាល់តែអស់អ្នកប្រឆាំងតែម្តង។ ពលរដ្ឋខ្មែរដែលមានប្រាជ្ញាស្មារតីភ្លឺស្វាងជាងគណបក្សប្រឆាំង ទោះបីគេមានអាយុតិចឬ

លើសពី៣០ឆ្នាំក៏គេស្គាល់ក្រយៅហ៊ុន-សែន និងគូកនគាត់ជាងអ្នកណាទៀតទាំងអស់។ ហេតុដូច្នេះហើយបានជាពលរដ្ឋខ្មែរត្រៀមខ្លួនជាស្រេចដើម្បីដើរឲ្យហួសពីជម្លោះនយោបាយ និង នយោបាយតថ្លៃគ្នារវាងបក្សទាំងពីរទៅទៀត។ គឺនៅក្នុងន័យនេះហើយដែល ក្រុមប្រឹក្សាអន្តរកាលប្រជាធិបតេយ្យ ត្រូវបានបង្កើតឡើង។ រីឯកម្មវត្ថុនៃក្រុមប្រឹក្សានេះ គឺការតស៊ូប្រឆាំងនឹងអាណានិគមយួននិងចិនតែម្តងដោយទាមទារដាច់ខាតឲ្យអនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ឆ្នាំ១៩៩១។ ទោះជានៅក្នុងករណីណាក៏ដោយ សហគមន៍អន្តរជាតិដឹងច្បាស់លាស់ថា គឺជាការដែលគេត្រូវលើកឡើងជាកំហិត ៖ ប្រទេសកាន់លទ្ធិប្រជាធិបតេយ្យនៅក្នុងលោកមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោះ ដែលអ្នកបន្លំនិងប្លន់សន្លឹកឆ្នោតបានប្រកាសនោះទេ ហើយយកចិត្តទុកដាក់នឹងការទាមទាររបស់អ្នកធ្វើបាតុកម្ម។ នៅពេលដែលរបបនៃអ្នកកាន់អំណាចខុសច្បាប់នេះក្លាយទៅជារបប ប៉ុល-ពតទី២ សូម្បីតែប្រទេសចិនក៏មិនចង់បានប៉ុន្មានដែរ ដោយប្រទេសនេះមិនចង់ចូលទៅ ឲ្យគេកាត់ក្តីម្តងទៀតឡើយ ព្រោះរបបខ្មែរក្រហមដែលត្រូវបានចិនកាន់ខ្សែញាក់បានកាប់សម្លាប់បញ្ញវន្តយ៉ាងរង្គាល ធ្វើឲ្យចិនបាក់មុខបាត់កិត្យានុភាពម្តងរួចមកហើយរហូតមកទល់នឹងពេលនេះ។

## ៨- ទស្សនវិស័យ

ថ្ងៃទី២៣កញ្ញាឆ្នាំ២០១៣ អ្វីដែលគេហៅថាអង្គប្រជុំលើកដំបូងនៃរដ្ឋសភាជាតិនីតិកាលទី៥ ត្រូវបានកោះប្រជុំដោយគ្មានវត្តមាននៃតំណាងរាស្ត្របក្សប្រឆាំង។ តាមការពិត រដ្ឋសភាបែបនេះខុសច្បាប់ទាំងស្រុង ព្រោះរំលោភលើគោលការណ៍នៃរដ្ឋធម្មនុញ្ញ និង បានរំលោភលើស្មារតីនៃសន្ធិសញ្ញាក្រុងប៉ារីស៍យ៉ាងជាក់ស្តែង។ ព្រះមហាក្សត្រខ្មែរបានទទួលបញ្ជាពីប៉េកាំងនិងហាណូយ ឲ្យធ្វើជាអធិបតីនៃអង្គប្រជុំលើកដំបូងខុសច្បាប់នេះទៀតផង។ មិនតែប៉ុណ្ណោះ រដ្ឋសភាខុសច្បាប់នេះមិនទាន់ជ្រើសតាំងអនុប្រធានសភា និងគណកម្មការនានាផង ស្រាប់តែហ៊ុន-សែនតែងតាំងខ្លួនឯងជានាយករដ្ឋមន្ត្រីតែម្តង គឺមិនខ្វីរង់ចាំព្រះមហាក្សត្រតែងតាំងខ្លួន

ឡើយ ដោយមុនដំបូងសំអាងទៅលិខិតរបស់ព្រះមហាក្សត្រដែលគ្មានទាំងហត្ថលេខា គ្មានទាំងត្រា។ នេះសបញ្ជាក់ឲ្យឃើញថា ជាឱសានវាទមួយចាប់បង្ខំឲ្យព្រះមហាក្សត្រធ្វើខុសម្តងទៀត ដោយរំលោភនីតិវិធីនិងច្បាប់ទម្លាប់គ្រប់បែបយ៉ាង ហើយបើស្តេចខ្មែរគិតតែពីធ្វើខុសច្បាប់ទម្លាប់បែបនេះ តើរាជានិយមខ្មែរអាចមានអត្ថិភាពតទៅទៀតឬអាចចាំបាច់ចំពោះរាស្ត្រខ្មែរឬទេ? បញ្ហាដែលគេអាចចោទសួរ គឺថា បើបុរសផ្តាច់ការ ហ៊ុន-សែន ស្អប់ប្រជាធិបតេយ្យដល់ថ្នាក់នេះទៅហើយ ហេតុដូចម្តេចក៏មិនប្រកាសថា ខ្លួនជាអ្នកដឹកនាំឯកបក្សតែម្តងទៅ ចាំបាច់អ្វីខំយករូបភាពក្រៅនៃរបបប្រជាធិបតេយ្យមកធ្វើជារបាំងនោះ? នេះជាសំនួរស្រួលឆ្លើយទេ៖ គឺដើម្បីបោកពលរដ្ឋខ្មែរដែលមានជំនឿដ៏ជ្រាលជ្រៅទៅលើលទ្ធិប្រជាធិបតេយ្យ។ នៅថ្ងៃនោះ ឯកអគ្គរដ្ឋទូតអាមេរិកដែលមាន វត្តមាននៅអង្គប្រជុំបានថ្លែងថា វត្តមានរបស់លោក ពុំមានន័យថាសហរដ្ឋអាមេរិកទទួលស្គាល់លទ្ធផលនៃការបោះឆ្នោះនោះទេ។ វ៉ាស៊ីងតោនក៏ដូចសហភាពអឺរ៉ុបដែរ បានប្រាប់ឲ្យដឹងរួចជាស្រេចថា គេស្នើសុំឲ្យពិនិត្យភាពមិនប្រក្រតីដែលមាននៅក្នុងការបោះឆ្នោតសិន គឺភាពមិនប្រក្រតីដែលគណបក្សប្រឆាំងបានប្តឹង ឬមួយក៏រង់ចាំការស្រុះស្រួលគ្នាណាមួយរវាងគណបក្សទាំងពីរនេះសិនដែរ។

យោងទៅតាមហេតុផលទាំងឡាយនេះ គេអាចគិតឃើញថា ក្រៅពីប៉េកាំង ហាណូយ ព្យុងយ៉ាង ឡាហាវ៉ាន និង ម៉ូស្គូ ព្រមទាំងប្រទេសមួយចំនួនដែលរកស៊ីជាមួយរបបហ៊ុន-សែន រដ្ឋាភិបាលខ្មែរដែលទើបនឹងតែងតាំងខ្លួនឯងដោយខុសច្បាប់នេះ ពុំអាចមានប្រទេសប្រជាធិបតេយ្យណាមួយនៅក្នុងលោកនេះទទួលស្គាល់បានឡើយ ហើយដូច្នេះ រដ្ឋាភិបាលនេះគ្មានជម្រើសអ្វីក្រៅពីដើរតាមផ្លូវដែលប៉ុល-ពតបានដើររួចមកហើយនៅឆ្នាំ១៩៧៥-១៩៧៩នោះទេ។ រឿងបែបនេះជាឧទាហរណ៍ដ៏អាក្រក់បំផុតចំពោះប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ ដែលទោះបីស្ថិតនៅក្រោមឃ្នាបសេដ្ឋកិច្ចរបស់ចិនក្តី ក៏នឹងរិះរកមធ្យោបាយចាត់វិធានការណ៍ដែលគេត្រូវតែធ្វើដែរ ដូចជាទណ្ឌកម្មពាណិជ្ជកម្មនិងសេដ្ឋកិច្ច ការផ្តាច់ជំនួយដែលគេត្រូវផ្តល់ឲ្យកម្ពុជា នៅលើមូលដ្ឋានកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ឆ្នាំ១៩៩១

ជាដើម។ ទោះជាយ៉ាងណាក្តី ប្រទេសចិនមិនអាចជួយប្រទេសកម្ពុជាបានទៀង ទាត់និងរហូតនោះទេ។ ប៉េកាំងគ្មានជម្រើសអ្វីក្រៅពីគ្រប់គ្រងស្រុកខ្មែរដូចឃុំមួយ របស់គេទេ។ ដូចយើងបានដឹងរួចមកហើយ នៅក្នុងឃុំទាំងនោះរបស់ចិនដែល មានកូរ៉េខាងជើងជាឧទាហរណ៍ស្រាប់ ប្រជាជនក្រីក្រទុរគត រស់នៅក្នុងភាពមិនគួរ គប្បី នៅក្បែរពួកអ្នកមានមហាចក្រគ្រាក់ៗ ពួកសហគ្រិនធំៗ និង ពួកកម្មាភិបាល បក្សកុំម្មុយនិស្តដែលមានប្រាក់រាប់ពាន់លាន។ រីឯប្រទេសយួនវិញ គេយកអនុផល និងវត្ថុធាតុដើមរបស់ខ្មែរទៅលក់នៅបរទេសកាន់តែច្រើនជាងមុនថែមទៀត ពោល គឺរបៀប៉ទទួលការបន្តពីចៅកែធំ៉។

ទស្សនវិស័យផ្សេងទៀតគឺភូមិសាស្ត្រនយោបាយ។ គ្មានអ្វីដែលអាចបញ្ជាក់ថា ការប្រជែងកម្លាំងនៅក្នុងតំបន់មិនអាចផ្លាស់ប្តូរបាននោះទេ នៅពេលខាងមុខ។ ប្រវត្តិសាស្ត្រពោរពេញទៅដោយហេតុផល ដែលមិនអាចទាយត្រូវទុកជាមុនបាន ទេ។ ប្រទេសចិនកំពុងតែស្រវឹងនឹងភាពខ្លាំងក្លាផ្នែកសេដ្ឋកិច្ចរបស់គេ គឺភាពខ្លាំង ក្លាដែលចេញមកពីប្រព័ន្ធសេដ្ឋកិច្ចមូលធននិយមមួយបែប ដែលមិនគោរពសិទ្ធិ មនុស្ស។ ការស្រវឹងនេះ នាំឲ្យគេមានមហិច្ឆតា អនុត្តរភាពមួយដ៏ធំអស្ចារ្យនៅក្នុង តំបន់ទាំងមូល ឬនៅក្នុងពិភពលោកផងក៏អាចថាបាន។ ទស្សនវិស័យនេះពុំមែន ជាការលើកឡើងដោយគ្មានមូលដ្ឋានច្បាស់លាស់នោះទេ ព្រោះអ្នកណាក៏គេដឹង រឿងនេះដែរ។ ការរីកចម្រើនសេដ្ឋកិច្ចនៃប្រទេសចិន បានមកពីការខំប្រឹងហួស ហេតុពេក។ ប្រទេសនេះចង់ធ្វើជាអ្នកលក់ផលិតផលប្រើប្រាស់ប្រចាំថ្ងៃតែម្នាក់ឯង នៅលើទីផ្សារពិភពលោកទាំងមូល។ ដើម្បីអាចធ្វើយ៉ាងនេះទៅកើត គឺមានតែផ្លូវ មួយប៉ុណ្ណោះ គឺដើរធ្វើអាណានិគមកិច្ចគ្រប់ច្រកល្ហក ពោលគឺដើរប្លន់ភោគទ្រព្យ ធម្មជាតិរបស់ប្រទេសចំណុះយ៉ាងសាហាវព្រៃផ្សៃបំផុត។ បើមិនធ្វើដូច្នេះទេ គឺគ្មាន វិធីឯណាទៀតឡើយ ហើយជាវិធីដែលមហាអំណាចបស្ចិមប្រទេសធ្លាប់បានប្រើ កន្លងមក។ គឺនៅពេលនោះហើយដែលយើងនឹងឃើញប្រតិកម្មពីសំណាក់ប្រទេស ដែលទទួលរងគ្រោះដោយចក្រភពកណ្តាលនេះ។ ពួកគេនឹងធ្វើការតស៊ូអស់ទំហឹង ជាមួយប្រទេសនានាឯទៀតដែលទទួលរងគ្រោះដូចគ្នា។ គឺមិនខុសអ្វីពីការតស៊ូ

ជំនាន់ពួកអាណានិគមនិយមសម័យមុននោះទេ។ ម៉្យាងទៀត ចិនជាប្រទេសមិនគោរពសិទ្ធិមនុស្សត្រឹមត្រូវអាចឲ្យគេទ្រាំទ្របាន។ ពេលនោះអ្នកដែលកំពុងគាំទ្រចិនដោយយល់ថា ប្រទេសនេះមានលក្ខណៈសម្បត្តិអាចយកជាគ្នាបាន នឹងភ្ញាក់រលឹកជាមិនខាន កាលបើដឹងថា តាមការពិតចិនកំពុងតែគំរាមដល់លទ្ធិប្រជាធិបតេយ្យនៅក្នុងលោក ពោលគឺប្រជាជាតិជាមាតុប្រទេសរបស់ពួកគេ គឺមិនខុសពីរបបណាហ្ស៊ីនាឆ្នាំ១៩៣៩-១៩៤៥នៅអឺរ៉ុបសោះឡើយ។ លុះអនាគតដ៏ខ្មៅងងឹតនេះមកដល់ប្រទេសមហាអំណាចសេដ្ឋកិច្ចទី២នៅក្នុងលោកនេះ មិនត្រឹមតែត្រូវបានប្រទេសនានាឯទៀតក្នុងលោកថ្កោលទោសប៉ុណ្ណោះទេ តែសូម្បីតែប្រជាជនចិនខ្លួនឯងជំនាន់ក្រោយ ដែលសព្វថ្ងៃនេះកំពុងត្រូវពួកអាជ្ញាធរធ្វើទារុណកម្ម ក៏នឹងថ្កោលទោសដែរ។

លទ្ធិប្រជាធិបតេយ្យ ការចង់បានសេរីភាពរបស់បុគ្គលម្នាក់ៗ ពោលគឺសិទ្ធិមនុស្សជាអាវុធមួយដ៏មានថាមពលខ្លាំងក្លាសម្រាប់បណ្ដាប្រជាជននៅអាស៊ី ដែលត្រូវចិនកំពុងតែយកមកធ្វើជាបរិវា។ វាសនារបស់សហភាពសូវៀត ការរលំរលាយនៃកំផែងទីក្រុងប៊ែរឡាំងជាឧទាហរណ៍មួយយ៉ាងជាក់ស្ដែង។ ការពិតបស្ចិមប្រទេសដែលកំពុងចុះខ្សោយផ្នែកសេដ្ឋកិច្ច នៅតែរក្សាទុកជានិច្ចកម្លាំងយោធា និងបច្ចេកវិជ្ជារបស់គេរង់ចាំតែឱកាសល្អប៉ុណ្ណោះ ដើម្បីបង្ហាញឲ្យឃើញថា ចក្រភពទាំងឡាយណាដែលកសាងនៅលើការភូតភរ នៅលើពលីកម្មឥតថ្ងៃចប់របស់ប្រជាជន នៅលើការរំលោភសិទ្ធិជាមូលដ្ឋានរបស់មនុស្ស មិនអាចស្ថិតស្ថិរបានទេ។ បទពិសោធន៍បែបនេះ ដែលមានចារទាំងអស់នៅក្នុងមេរៀនប្រវត្តិសាស្ត្រក្នុងពិភពលោកទាំងមូលគ្មានអ្នកណាស្គាល់ច្បាស់ជាងបស្ចិមប្រទេសទេ។

## ៩- រដ្ឋាភិបាលដែលគ្មានប្រជាពលរដ្ឋគាំទ្រ និង រដ្ឋាភិបាលដែលមានប្រជាពលរដ្ឋគាំទ្រ

ដូចយើងបានបង្ហាញឲ្យឃើញនៅខាងលើស្រាប់ អ្នកដែលកំពុងគាំទ្រហ៊ុន-សែន នៅពេលនេះ នឹងនាំគ្នាមកចូលរួមចំណែកជាមួយអ្នកប្រឆាំងនៅក្នុងពេលប៉ុន្មានថ្ងៃ ឬប៉ុន្មានខែខាងមុខនេះដោយគេចពុំផុត។ រដ្ឋាភិបាលដើម្បីប្រជាជន ដឹកនាំដោយប្រជាជនខ្លួនឯងកំពុងរៀបចំដំណើរការជាបណ្តើរៗ ហើយនឹងចេញឲ្យឃើញនៅពេលសមស្របខាងមុខ។ បើហ៊ុន-សែន និងបក្សពួកនៅតែមានៈបន្តធ្វើអ្វីដែលគេកំពុងតែធ្វើទីក្រុងភ្នំពេញ នោះពួកគេនឹងត្រូវកាត់ផ្តាច់ចេញពីលោកសេរី ហើយប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យនឹងចាត់វិធានការធ្វើទណ្ឌកម្មកម្ពុជា។

ទស្សនៈវិស័យនេះ តាមការពិតមិនធ្វើឲ្យរដ្ឋាភិបាលដែលប្រកាសខ្លួនដោយខ្លួនឯងនេះមានសុទិដ្ឋិនិយមប៉ុន្មានទេ បើគណបក្សប្រឆាំងមិនចាញ់បោក ឬនាំគ្នាជួយស្តារនោះ។ ការខំបកស្រាយរដ្ឋធម្មនុញ្ញតាមភាសាកូតករ របៀបប៉ាហ៊ីមិនស៊ីលុយ មិនអាចឲ្យសហគមន៍អន្តរជាតិទទួលយកបានទេ។ ហ៊ុន-សែន មិនបានគិតដល់រឿងដែលថា រដ្ឋាភិបាលដែលត្រូវតែងតាំងឡើងដោយរដ្ឋសភាឯកបក្សនឹងនាំទៅរកការសើរើពិនិត្យ ការអនុវត្តន៍កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ឲ្យបានត្រឹមត្រូវវិញជាមិនខាន។ ប៉េកាំងនិងហាណូយ ដែលបានលើកទឹកចិត្តឲ្យហ៊ុន-សែនធ្វើដូច្នេះក៏មិនមែនមិនដឹងថាជាយន្តការកាំបិតចិតដងឯងនោះទេ តែដោយពួកគេធ្វើតាមតែចិត្តអភិមានរបស់គេ ហើយបានប្រមាថច្បាប់អន្តជាតិ និង អធិបតេយ្យរបស់ប្រទេសទន់ខ្សោយគ្មានបង្អែក គេមិនខ្វីរវល់នឹងរឿងនេះឡើយ។ រឿងប្រើភាសាកូតករមួយទៀត គឺប្រតិកម្មរបស់រដ្ឋមន្ត្រីការបរទេសនៃរដ្ឋាភិបាលខុសច្បាប់នោះ ៖ ពេលដែលលោកលើកពីគោលការណ៍ស្តីពីការណ៍ដែលបរទេស គ្មានសិទ្ធិលូកដៃចូលកិច្ចការផ្ទៃក្នុងកម្ពុជា លោកភ្លេចគិតថា គឺប៉េកាំង និង ហាណូយដែលជាចៅហ្វាយរបស់លោកទេ ដែលត្រូវលោករិះគន់មុនគេបង្អស់ ហើយមួយវិញទៀតលោកភ្លេចទាំងស្រុងថា ប្រទេសកម្ពុជានៅជាសមាជិកពេញសិទ្ធិរបស់អង្គការសហប្រជាជាតិ និងរបស់សហគមន៍អាស៊ាននៅឡើយ។ បើបាតុករមិនរៀបចំខ្លួនឥឡូវនេះទេ អ្នកដែលបានបោះឆ្នោតឲ្យគណបក្សប្រឆាំងនៅពេលថ្មីៗ នេះនឹងត្រូវពួកផ្តាច់ការហ៊ុន-សែនគាបសង្កត់ធ្វើបាបធ្វើទារុណកម្មដ៏ខ្លោចផ្សាបន្តមកទៀត ដូចជា

ការសង្កត់សង្កិនតាមគ្រប់រូបភាព មានការកាប់សម្លាប់ ការលួចធ្វើឃាតដោយកំបាំង ការចោទប្រកាន់យកទៅដាក់គុកច្រវ៉ាក់ដោយគ្មានកំហុសជាដើម...។

រដ្ឋាភិបាលដែលទើបនឹងតែងតាំងដោយរដ្ឋសភាមួយ ដែលគ្មានការចូលរួមពីអ្នកតំណាងគណបក្សប្រឆាំងទាំងអស់ជារដ្ឋាភិបាលខុសច្បាប់។ កាលណាប្រទេសមួយគ្មានរដ្ឋាភិបាលត្រឹមត្រូវតាមច្បាប់នោះទេ ប្រទេសនោះត្រូវបានចាត់ទុកថាគ្មានរដ្ឋាភិបាលតែម្តង។ បើរយៈពេល៦០ថ្ងៃបានកន្លងផុតទៅហើយ ប្រទេសកម្ពុជានៅតែគ្មានរដ្ឋាភិបាលត្រឹមត្រូវតាមផ្លូវច្បាប់ដដែល គេអាចនិយាយបានថាប្រទេសទាំងមូលគ្មានរដ្ឋាភិបាលឡើយ គឺរហូតដល់ពេលបោះឆ្នោតលើកក្រោយនៅក្នុងស្ថានភាពថ្មី។ ប្រទេសដែលគ្មានរដ្ឋាភិបាល ជាប្រទេសដែលធ្លាក់ទៅក្នុងអានាធិបតេយ្យ។ គឺដើម្បីចៀសវាងស្ថានការណ៍បែបនេះហើយដែលក្រុមប្រឹក្សាអន្តរកាលប្រជាធិបតេយ្យ បានត្រូវបង្កើតឡើង។ គឺជាស្ថាបន័មួយដែលមានតស្សូរជនប្រជាធិបតេយ្យ ចលនាប្រជាធិបតេយ្យ និង គណបក្សនយោបាយប្រជាធិបតេយ្យនានា ដែលទាមទារឲ្យមានការគោរពគោលការណ៍ប្រជាធិបតេយ្យ គោរពសិទ្ធិមនុស្សនិងពលរដ្ឋ បានរួបរួមគ្នាបង្កើតជាបណ្តោះអាសន្នសិនទម្រាំចាត់តាំងការបោះឆ្នោតឲ្យបានត្រឹមត្រូវនៅពេលខាងមុខ ដើម្បីដឹកនាំប្រទេសឲ្យវិលមករកនិត្យានុកូលភាពដែលមានសហគមន៍អន្តរជាតិទទួលស្គាល់វិញ និងរៀបចំប្រទេសឲ្យក្លាយជាប្រទេសនីតិរដ្ឋគំរូ រំដោះខ្លួនចេញពីអាណានិគមន៍យួននិងចិនដោយទាមទារឲ្យមានការអនុវត្តន៍យ៉ាងជាក់ស្តែង នូវគ្រប់គោលការណ៍នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ឆ្នាំ១៩៩១ តាមការចង់បានរបស់ពលរដ្ឋខ្មែរ។ ក្រុមប្រឹក្សានឹងចេញផ្សាយកម្មវិធីនយោបាយនៅពេលឆាប់ៗខាងមុខនេះ។

ភ្នំពេញ ថ្ងៃទី 20 តុលា ឆ្នាំ២០១៣

ក្រុមប្រឹក្សាអន្តរកាលប្រជាធិបតេយ្យ

ទំនាក់ទំនង ៖ transitionaldemocraticcouncil@gmail.com

ក្រុមប្រឹក្សាអន្តរកាលប្រជាធិបតេយ្យ

បោះពុម្ពផ្សាយនៅខែតុលាឆ្នាំ២០១៣

ទំនាក់ទំនង៖ transitionaldemocraticcouncil@gmail.com